# វិធីប្រើ
# វណ្ណយុត្តិ នឹងខណ្ឌសញ្ញា

ACCENTS ET SIGNES DE PONCTUATION



ព.ស. ២៤៩៨ គ.ស. ១៩៥៥

បណ្ណាគារ ប៊ុក-គាង ភ្នំពេញ

CA 15

le 21 Sept. 1956
Watanabé
Ambassade du Japon
à
Phnom-Penh

# វិធីប្រើ

# វណ្ណយុត្តិ និង ខណ្ឌសញ្ញា

# វិធីប្រើ

# វណ្ណយុត្តិ និង ខណ្ឌសញ្ញា


រៀបរៀងដោយ

ឆួន - ប៊ុត

---

ព្រះគ្រូសង្ឃសត្ថា ប៊ុណ្យ-សុម្ភាជ (ជម្ពាភមោ)

សាស្ត្រាចារ្យសំស្ក្រឹត នៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត

និងជា

គណៈកម្មការវប្បធម៌

ព្រះមហា ញ៉ុក-ថែម

សាស្ត្រាចារ្យភាសាខ្មែរ នៅវិទ្យាល័យព្រះស៊ីសុវត្ថិ

ពិនិត្យផ្ទៀងផ្ទាត់


---


បោះពុម្ពលើកទី ១

បំនួន ២.០០០ ច្បាប់

ព. ស. ២៤៩៨, គ. ស. ១៩៥៥



ទុកសិទ្ធិ

# កថាមុខ

ដើម្បីសរសេរនឹងតែងសេចក្ដីជាភាសាខ្មែរឲ្យបានត្រឹមត្រូវទៀងទាត់ អ្នកសិក្សាភាសាជាតិត្រូវតែចេះរបៀបវេយ្យាករណ៍ខ្មែរ, ដូចជា: អក្ខរាវិរុទ្ធ, វណ្ណយុត្តិនឹង ខណ្ឌសញ្ញា នេះជាដើម ឲ្យបានម៉ត់ចត់ពិតប្រាកដ ទើបគេអាចនិយាយ, សរសេរ ឬ បោះពុម្ពភាសាជាតិបានត្រឹមត្រូវមានរបៀបរៀបរយតាមបែបបទដែលលោកបានបញ្ញត្តិទុកមក ។

វណ្ណយុត្តិ នឹង ខណ្ឌសញ្ញា ជាផ្នែកមួយនៃវេយ្យាករណ៍ខ្មែរ ដែលខ្ញុំបានផ្ដើមរៀបរៀងឡើងនេះ ដោយមានសង្ឃឹមថានឹងបានជាប្រយោជន៍ដល់អ្នកសិក្សាភាសាជាតិ នៅឱកាសដែលប្រទេសជាតិកំពុងបង្ខំពង្រីកភាសាជាតិ ឲ្យបានរីកធំទូលំទូលាយឡើងក្នុងសម័យប្រទេសជាតិបានទទួលឋានៈជារដ្ឋឯករាជ្យបរិបូណ៌មួយក្នុងពិភពលោក ។

វណ្ណសញ្ញា នឹង វណ្ណយុត្តិ ដែលខ្ញុំបាន រៀបរៀងឡើងនេះ មានសេចក្ដីពន្យល់អំពីវិធីប្រើ ព្រមទាំង ឧទាហរណ៍សព្វគ្រប់ ល្មមសម្រេចប្រយោជន៍ដល់អ្នក សិក្សាភាសាជាតិគ្រប់ជាន់គ្រប់ថ្នាក់បាន ។

មួយវិញទៀត វណ្ណសញ្ញា នឹង វណ្ណយុត្តិ នេះ ខ្ញុំបានដកស្រង់អំពីច្បាប់ទាំងឡាយមាន វចនានុក្រមខ្មែរ ជាដើម ដែលលោកអ្នកប្រាជ្ញបានរៀបរៀង ទុកមកហើយ ព្រមទាំងបានរៀបរៀងបន្ថែមខ្លះទៀត ដើម្បី បង្រួបបង្រួមក្នុងការប្រើប្រាស់ភាសាជាតិ តាមសម័យនិយម ។

នៅទីបំផុត, ខ្ញុំសូមឧទ្ទិសសៀវភៅនេះ ដល់យុវជន ខ្មែរក្នុងកម្ពុជរដ្ឋទាំងមូល ឲ្យបានចំរើនល្អគលាស់ដុះដាល ដោយវិជ្ជាអក្សរសាស្ត្រជាតិគ្រប់ៗ គ្នាកុំបីអាក់ខានឡើយ!

ភ្នំពេញ, នៅថ្ងៃអាទិត្យ ១៥ កើត ខែជេស្ឋ ឆ្នាំមមែសប្ដស័ក

២៤៩៨

ត្រូវនឹងថ្ងៃទី ៥ ខែមិថុនា ———

១៩៥៥

ជួន-ប៊ុត

# បញ្ជីមាតិកា


មាតិកានុក្រម ទំព័រ

## វណ្ណយុត្តិ

ពាក្យថាវណ្ណយុត្តិ . . . . . . . . . . . . . . . . . . . . . ១
វណ្ណយុត្តិចែកចេញជាពីរពួក . . . . . . . . . . . . . . . . ១
វណ្ណយុត្តិ ១១ យ៉ាង . . . . . . . . . . . . . . . . . . . ២
ខណ្ឌសញ្ញា ២០ យ៉ាង . . . . . . . . . . . . . . . . . . ៤

## វិធីប្រើវណ្ណយុត្តិ

រស្សសញ្ញា ឬ បន្តក់ . . . . . . . . . . . . . . . . . . . ៦
មូសិកទន្ត ឬ ធ្មេញកណ្ដុរ . . . . . . . . . . . . . . . . ៩
ត្រីស័ព្ទ . . . . . . . . . . . . . . . . . . . . . . . . ១៣
សំយោគសញ្ញា . . . . . . . . . . . . . . . . . . . . . ២០
របាទ ឬ រេផៈ . . . . . . . . . . . . . . . . . . . . . ២៤
ទណ្ឌឃាត ឬ បដិសេធ . . . . . . . . . . . . . . . . . ២៧
លេខអស្ដា . . . . . . . . . . . . . . . . . . . . . . . ៣២
វិសជ្ជនីយ ឬ វិសគ៌ៈ ឬ រះមុខ . . . . . . . . . . . . ៣៤
យុគលពិន្ទុ . . . . . . . . . . . . . . . . . . . . . . . ៤០
កាកបាទ ឬ ជើងក្អែក . . . . . . . . . . . . . . . . . ៤៧
លេខទោ ឬ អាមេណ្ឌិតសញ្ញា . . . . . . . . . . . . . ៥០

កុក្កុដនេត្រ ឬ ភ្នែកមាន់ ........................ ៥៣
ខណ្ឌ ឬ ល្បះ ........................ ៥៥
ល្បះចប់ ឬ ល្បះបរិយោសាន ........................ ៥៨
គោមូត្រ ........................ ៦០
វ៉ាត់ ឬ ឃ្នាប ........................ ៦២
រជ្ជុសញ្ញា (យតិភង្គ, នយសញ្ញា) ........................ ៦៤
មជ្ឈណ្ឌសញ្ញា ឬ ពងត្រី ........................ ៧៤
បេយ្យាល ........................ ៧៨
អាទិសង្កេត ........................ ៧៩
ក្បៀស ........................ ៨១
បំណុចក្បៀស ........................ ៨៣
បំណុចពីរគូស ឬ ទ្វិពិន្ទុលេខ ........................ ៨៥
បុច្ឆនសញ្ញា ........................ ៨៧
ឧទានសញ្ញា (អច្ឆរិយសញ្ញា, វិម្ហយ–, សំវេគ–) ........................ ៨៩
វិឡារសញ្ញា ឬ អញ្ញប្រកាស ........................ ៩២
អន្តរសញ្ញា ........................ ៩៤
វង់ក្រចក ឬ នខសញ្ញា ........................ ៩៧
វង់ជង្កៀប ........................ ៩៩
វង់ក្រចកចំហៀង ឬ អឌ្ឍនខសញ្ញា ........................ ១០២
អវគ្រហសញ្ញា ........................ ១០៥
បកិណ្ណកសញ្ញា ........................ ១០៨

# វណ្ណយុត្តិ

ក្នុងភាសាខ្មែរ មានសញ្ញាទាំងឡាយសម្រាប់ប្រើបន្ថែម ឬប្រើផ្សំជាមួយនឹងអក្សរ ដើម្បីលំអៀងស័ព្ទដើមឲ្យប្លែកពីលំនាំដើមក៏មាន សម្រាប់ប្រើខណ្ឌសេចក្ដីឲ្យដាច់ជាសង្កាត់ៗ ឲ្យមានរបៀបជាឃ្លា ល្បះ ឬជាប្រយោគនីមួយៗ ដើម្បីឲ្យងាយស្ដាប់កុំឲ្យច្រឡំសេចក្ដីក៏មាន សញ្ញាទាំងអម្បាលណោះមាន ២ ពួកគឺ ៖

១) ពួកសញ្ញាដែលប្រើលើតួអក្សរ ឬប្រើផ្សំជាមួយនឹងអក្សរ ដើម្បីបំផ្លែងតួអក្ខរៈ ឬស័ព្ទដើម ឲ្យមានសំឡេងប្លែកពីលំនាំដើម លោកហៅថា វណ្ណយុត្តិ (សញ្ញាសម្រាប់ប្រើប្រកបនឹងអក្សរ) ត្រូវនឹងពាក្យបារាំងថា (Accents) ។

២) ពួកសញ្ញាដែលប្រើខណ្ឌសេចក្ដីឲ្យមានរបៀបជាឃ្លាជាសង្កាត់ ដើម្បីធ្វើសេចក្ដីឲ្យមានន័យកាន់តែជាក់ច្បាស់ឡើង លោកហៅថា ខណ្ឌសញ្ញា (សញ្ញាសម្រាប់ប្រើខណ្ឌសេចក្ដី) ត្រូវនឹងពាក្យបារាំងថា (Signes de ponctuation) ។

## វណ្ណយុត្តិមាន ១១ គឺ:

១.— រស្សសញ្ញា ឬ បន្តក់ ( ់ )

២.— មូសិកទន្ត ឬ ធ្មេញកណ្ដុរ ( ៉ )

៣.— ត្រីស័ព្ទ ( ៊ )

៤.— សំយោគសញ្ញា ( ័ )

៥.— របាទ ឬ រេផះ ( ៌ )

៦ — ទណ្ឌឃាត ឬ បដិសេធ ( ៍ )

៧.— លេខអស្ដា ( ៏ )

៨.— វិសជ្ជនីយ ឬ វិសគ៌ះ ឬ រះមុខ ( ះ )

៩.— យុគលពិន្ទុ ( ៈ )

១០.— កាកបាទ ឬ ជើងក្អែក ( + )

១១.— លេខទោ ឬ អាមេណ្ឌិតសញ្ញា ( ៗ )

### ក) សំនួរ

ដូចម្ដេចដែលហៅថា វិណ្ណយុត្តិ? វិណ្ណយុត្តិ មានប៉ុន្មានយ៉ាង? ហៅអ្វីខ្លះ? ចូរកប់ឈ្មោះមកមើល? លេខអស្ដា នឹង ទណ្ឌឃាត មានទ្រង់ទ្រាយដូចគ្នា ឬ ប្លែកគ្នា? វិសជ្ជនីយ នឹង យុគលពិន្ទុ មានទ្រង់ទ្រាយដូចគ្នា ឬ

ប្លែកគ្នា? ចូរនាំយករូបគំនូសសញ្ញាដែលសួរខាងលើនេះ

មកសរសេរពន្យល់ហើយប្រាប់ឈ្មោះមកផង?

ការហាត់:

១.– ចូរស្រង់យកពីបទខាងដើមនេះ ចំពោះវណ្ណយុត្តិទាំងឡាយដែលអ្នកបានឃើញ,

(១)

១) ចម្លើយ

| |
|---|
| |

*

* *

---

(១) ពាក្យ " ចម្លើយ " យើងមិនបាននាំយកមកឆ្លើយក្នុងទីនេះទេ ដោយទុកឲ្យអ្នកសិក្សារិះរកយោបល់ឆ្លើយដោយខ្លួនឯង ។

# ១ ណ្ណាសញ្ញាមាន ២០ គឺ:

| | | |
|---|---|---|
| ១.— | កុក្កុដនេត្រ ឬ ភ្នែកមាន់ . . . . . . . . . . . | ( ៙ ) |
| ២.— | ខណ្ឌ ឬ ល្បះ . . . . . . . . . . . . . . | ( ។ ) |
| ៣.— | ល្បះចប់ ឬ ល្បះបរិយោសាន . . . . . . . . | ( ៕ ) |
| ៤.— | គោមូត្រ . . . . . . . . . . . . . . | ( ៚ ) |
| ៥.— | វ៉ាត់ ឬ ឃ្នាប . . . . . . . . . . . . . | ( ⌇ ) |
| ៦.— | រជ្ជុសញ្ញា (យតិភង្គ, នយសញ្ញា) . . . . . . . | ( – ) |
| ៧.— | មច្ឆណ្ឌសញ្ញា ឬ ពងត្រី . . . . . . . . . . . | ( ... ) |
| ៨.— | បេយ្យាល . . . . . . . . . . . . . | (។បេ។ ឬ ។ល។) |
| ៩.— | អាទិសង្កេត . . . . . . . . . . . . . | ( . ) |
| ១០.— | ក្បៀស . . . . . . . . . . . . . . . | ( , ) |
| ១១.— | ចំណុចក្បៀស . . . . . . . . . . . . . | ( ; ) |
| ១២.— | ចំណុចពីរគូស ឬ ទ្វិពិន្ទុលេខ . . . . . . . . . | ( ៖ ) |
| ១៣.— | បុច្ឆនសញ្ញា . . . . . . . . . . . . . | ( ? ) |
| ១៤.— | ឧទានសញ្ញា (អច្ឆរិយសញ្ញា, វិម្ហយ—, សំវេគ—) | ( ! ) |
| ១៥.— | វិឡារសញ្ញា ឬ អញ្ញប្រកាស . . . . . . . . | (“ ” ឬ « ») |
| ១៦.— | អន្តរសញ្ញា . . . . . . . . . . . . . . | ( ‘ ’ ) |
| ១៧.— | វង់ក្រចក ឬ នខសញ្ញា . . . . . . . . . . | ( ( ) ) |
| ១៨.— | វង់ដង្កៀប . . . . . . . . . . . . . . | ( [ ] ) |
| ១៩.— | វង់ក្រចកចំហៀង ឬ អឌ្ឍនខសញ្ញា . . . . . | ( ) ) |
| ២០.— | អវគ្រហសញ្ញា . . . . . . . . . . . | ( ᔑ ) |

ក) សំនួរ

ដូចម្ដេចដែលហៅថា ខណ្ឌសញ្ញា? ខណ្ឌសញ្ញាមានប៉ុន្មានយ៉ាង? ហៅអ្វីខ្លះ? ចូររាប់ឈ្មោះឲ្យសព្វគ្រប់មកមើល?

ការហាត់:

១.– ចូរស្រង់យកពីបទខាងដើមនេះ ចំពោះខណ្ឌសញ្ញាទាំងឡាយដែលអ្នកបានឃើញ,

២.– ចូរស្រង់យកចំពោះខណ្ឌសញ្ញាខែរសុទ្ធដែលអ្នកបានឃើញ,

៣.– ចូរស្រង់យកសញ្ញាសាកលដែលអ្នកបានឃើញ,

១) ចម្លើយ

*

*  *

# វិធីប្រើវណ្ណយុត្តិ

(១) ,

## (១) បន្តក់ (១)

វណ្ណយុត្តិមួយបែបមានសណ្ឋានកំបុតខ្លីយ៉ាងនេះ ( ់ ) សម្រាប់ប្រើបំបែកសំឡេងវែង ឲ្យខ្លីកំបុតធួន់, ប្រើដាក់បានចំពោះតែពីលើតួអក្សរប្រកបរបស់ពាក្យខ្មែរដែលជាស្រៈ អ, អា ពីរនេះ ហើយតួដែលប្រកបនោះជាអក្សរ ក, ង, ប, ញ, ត, ន, ប, ល, ស;

បន្តក់ធ្វើសំឡេងវែងឲ្យកំបុតខ្លី,

ឧទាហរណ៍:

កក > កក់, កង > កង់, ដាប > ដាប់, បាញ >

---

(១) ហៅថា "រស្សសញ្ញា" ក៏បាន ។

ចាញ់, កត > កត់, គាន > គាន់, បប > បប់, ដល

ដល់, ទាស > ទាស់, បង្កាក > បង្កាក់, ផ្កាល > ផ្កាល់,

ស្គាល > ស្គាល់;...

ពាក្យដែលជាប់មកពីបាលី ឬ សំស្រ្កឹត នោះបើពាក្យនោះកើតមកអំពីស្រៈ អ ឬ អា ហើយប្រកបនឹងអក្សរទាំង ៩ តួខាងលើនេះក្តី ក៏មិនត្រូវប្រើ បន្តក់ ( ់ ) នេះ ពីលើឡើយ,

ឧទាហរណ៍ :

កុសល, កុហក, ជន, ជាតក, តាបស, ទារក, ទិវង្គត, ធនធាន, បុរស, ផលានុផល, ពល, ភព, មគ្គផល, លាមក, សាកល, សុគត, អស្តង្គត ឧបាយកល, ឱជារស ... ជាដើម.

កុំសរសេរ បន្តក់ ពីលើជា: កុសល់, កុហក់, ជន់, ជាតក់ ... ... ... ដូច្នេះឡើយ ។

មួយវិញទៀត, ស្រៈ អា ប្រកបនឹងខ្យល់ ង ក៏មិនត្រូវប្រើ បន្តក់ ( ់ ) នេះ ពីលើឡើយ ត្រូវប្រើ និគ្គហិត ( ំ )នេះ ជំនួសវិញ,

ឧទាហរណ៍:

ក្ដាំង, ខ្លាំង, ឃ្លាំង, ប្យាំង, ឆ្នាំង,...:

កុំប្រើជា: ក្ដាង់, ខ្លាង់, ឃ្លាង់, ប្យាង់, ឆ្នាង់... ដូច្នេះឡើយ;

៣) សំនួរ

បន្តក់មានសណ្ឋានដូចអ្វី? សម្រាប់ប្រើយ៉ាងណាខ្លះ? ប្រើបានចំពោះតែពីលើស្រៈអ្វី? ប្រកបនឹងអក្សរប៉ុន្មានតួ? អក្សរអ្វីខ្លះ? ដូចឧទាហរណ៍ថាម៉េច? — ពាក្យដែលជាប់មកពីបាលីប្រើបន្តក់បានឬទេ? ដូចឧទាហរណ៍ថាម៉េច? ស្រៈ អា ប្រកបនឹងខ្យល់ ង ប្រើបន្តក់ពីលើបានឬទេ?

ការហាត់ៈ

ចូរស្រង់យកបទខាងលើ ចំពោះពាក្យណាដែលមាន

ប្រើបន្តក់ ( ់ ) នេះ ពីលើ;

១) ចម្លើយ

|  |
| --- |
|  |

*

* *

(១)
(២) ត្រីសព្ទ ( ៉ )

វណ្ណយុត្តិមួយបែបមានរូបជាគំនូសក្បៀសពីរ មាន

សណ្ឋានដូចធ្មេញកណ្ដុរយ៉ាងនេះ ( ៉ ) សម្រាប់ប្រើដាក់

ពីខាងលើ បំបែរសំឡេងស័ព្ទអក្សរ ឃោសៈ ឲ្យទៅជា

ស័ព្ទអក្សរ អឃោសៈ វិញ;

(១) ហៅថា "មូសិកទន្ត" ឬហៅតាម ព.សា.ថា "សម្ងាប់" ក៏បាន។

អក្សរដែលត្រូវបំបែរនោះមាន ៩ តួគឺៈ ង, ញ, ន, ប, ម, យ, រ, ល, វ ឲ្យមានសំឡេងទៅជាៈ ង៉, ញ៉, ន៉, ប៉, ម៉, យ៉, រ៉, ល៉, វ៉ ។

| |
|---|
| សម្រាប់ប្រើដាក់លើស្រៈ (ិ) ឲ្យទៅជាស្រៈ (ឹ), |

ឧទាហរណ៍ៈ

កិ > កឹ, ទិ > ទឹ, ជិ > ជឹ, បិ > បឹ, ងិ > ងឹ, ... ។

បើមាន ស្រៈ ម្ហ និគ្គហិត (ំ) នេះ នៅពីលើ, បណ្ឌិតវេយ្យាករណ៍លោកបង្គាប់ឲ្យផ្លាស់ ធ្មេញកណ្ដុរ (៉) នេះ ទៅជា ក្បៀស ក្រោម (ុ) វិញ,

ឧទាហរណ៍ៈ

ញុឹង, មុឹង, រុឹង, បុិន, បុឹ, បុឹង, បុឹម, ស្រុឹង, ញុាំង, យុាំង, រុាំង, ...;

កុំសរសេរជា: ញ៉ឺង, ម៉ឺង, រ៉ឺង, ប៉ឹន, ប៉ឺ, ប៉ឺង, ប៉ឹម, ប៉ើង, ញ៉ាំង, យ៉ាំង, រ៉ាំង ... ដូច្នេះឡើយ ។

បំណាំ:

១.– ចំពោះតួ "ប" ដែលជា អឃោសៈ ស្រាប់, កាលបើដាក់ មូសិកទន្ត ( ៉ ) នេះ នៅពីលើ ក៏គង់តែនៅជា អឃោសៈ ដដែល តែស័ព្ទប្ដូរពី "ប" គឺទៅជា ស័ព្ទ "ប៉" វិញ ។

២.– កាលបើមានពាក្យពីរព្យាង្គ ព្យាង្គខាងដើម ជាអក្សរ អឃោសៈ ព្យាង្គខាងចុងមិនត្រូវប្រើ មូសិកទន្ត ( ៉ ) នេះ ពីលើឡើយ,

ឧទាហរណ៍:

កញ្ញា, កន្ទាត, ក្រមា, ក្រេវមក្រវាម, ក្រវល់-ក្រវាយ, ក្រវែល, ខមាទោស, ប្រងេងប្រងាង,

ធាយា, ជរាប, ឋានា, តារា, តុលា, ថនា បរាជ័យ, បញ្ញា, ប្រមាត់, ប្រយោជន៍, ផលានុផល, សលាក, សាលា, ស្រងេះស្រងោប, ស្រវា ...

*កុំសរសេរសម្លាប់ពីលើជា:* កញ្ញ៉ា, កន្ល៉ាត, ក្រម៉ា, ក្រ៉ើមក្រ៉ឹម,.... ... *ដូច្នេះឡើយ ។*

## ក) សំនួរ

ធ្មេញកណ្ដុរ *ឬ* មូសិកទន្ត *មានទ្រង់ទ្រាយដូចម្ដេច? សម្រាប់ប្រើយ៉ាងណាខ្លះ? អក្សរ* ឃោសៈ *ដែលត្រូវបំបែរឲ្យទៅជា* អឃោសៈ *មានប៉ុន្មានតួ? ឈ្មោះអ្វីខ្លះ? បើមាន* ស្រៈ *ឬ* និគ្គហិត *នៅពីលើ លោកបង្គាប់ឲ្យផ្លាស់* ធ្មេញកណ្ដុរ *ទៅជាអ្វី? ដូចឧទាហរណ៍ថាម៉េច ។ កាលបើមានពាក្យពីរព្យាង្គ ព្យាង្គខាងដើមជា* អឃោសៈ *ព្យាង្គខាងចុងត្រូវ* សម្លាប់ *ឬទេ?*

ការហាត់:

១. - ចូររកពាក្យដែលមានប្រើមូសិកទន្ត;

១) ចម្លើយ

* * *

## (៣) ត្រីស័ព្ទ (៊)

វណ្ណយុត្តិមួយបែប មានសណ្ឋានដូចសក់កយ៉ាងនេះ (៊) សម្រាប់ប្រើដាក់លើអក្សរ ៤ តួ គឺ: ប, ស, ហ, អ ឲ្យមានសំឡេងធំជា: ប៊, ស៊, ហ៊, អ៊ (គឺធ្វើសំឡេង អឃោសៈ ឲ្យទៅជាសំឡេង ឃោសៈ),

ឧទាហរណ៍:

ឈ្មោះប៊ិន, ឈ្មោះប៊ីន, ត្បូងប៊ុត, ឈ្មោះប៊ុន,

ស៊ិងស្វា, ឮស៊ាន, ស៊ុនដំណើរ, កៅស៊ូ, មិនហ៊ាន, ក្រុមហ៊ុន, ស្រែកហ៊ោ, មាត់អ៊ូអា, ក្របអ៊ីត ជាដើម ។

បំណាំ:

១.– ត្រីស័ព្ទ ( ៊ ) នេះ កាលបើមានស្រៈនិស្ស័យគឺ: ( ិ ), ( ី ), ( ឹ ), ( ឺ ), ( ើ ), ( ុំ ), ( ាំ ) នេះ នៅពីលើ, បណ្ឌិតវេយ្យាករណ៍លោកបង្គាប់ឲ្យប្រើដូចពោលតទៅនេះ ៖

ក) តួ ប៊ិ កាលបើមាន ស្រៈនិស្ស័យ នៅពីលើ លោកហាមមិនឲ្យផ្លាស់ត្រីស័ព្ទ ( ៊ ) នេះ ទៅជា ក្បៀស ( ុ ) ក្រោមទេ ត្រូវទុក ត្រីស័ព្ទ ឲ្យគង់នៅពីខាងលើដដែល ដើម្បីកុំឲ្យស័ព្ទនោះក្លាយទៅជាអក្សរសម្លាប់,

ឧទាហរណ៍:

ឈ្មោះប៊ិន កាលបើផ្លាស់ត្រីស័ព្ទ ( ៊ ) នេះ ទៅជា

ក្បៀស (ុ) ក្រោម នឹងក្លាយពាក្យ ប៊ិង នេះ ទៅជា ប៊ុំង វិញ (គឺប៊ុនប្រសប់) ឬ ដូចជា ឈ្មោះប៉ី កាលបើផ្លាស់ត្រីស័ព្ទខាងលើទៅជាក្បៀសក្រោមវិញ នឹងក្លាយពាក្យ ប៉ី នេះ ទៅជា ប៊ី វិញ (គឺប៊ីដែលគេផ្ទុះ ប៊ុអ, ប៊ុពក) ។

១) តួ សិ កាលបើមាន ស្រៈនិស្ស័យ នៅពីលើ លោកបង្គាប់ឲ្យផ្លាស់ ត្រីស័ព្ទ (៊) នេះ ទៅជា ក្បៀស (ុ) ក្រោមវិញ,

ឧទាហរណ៍:

ឈ្មោះស៊ិន, ស៊ុបាយ, ម៉ាស៊ីន, ដែនកូស៊ាំង-ស៊ីន, ដើរស៊ើកៗ, សក់ស៊ើងព្រឹង, ស៊ើបការណ៍, ស៊ើសគ្រមើស, ស៊ាំបិទ, ស៊ាំគំនិត ជាដើម ។

ក) តួ ប៉ា កាលបើមាន ស្រៈនិស្ស័យ នៅពីលើ

លោកបង្គាប់ឲ្យប្រើបានទាំងពីរយ៉ាង គឺប្រើដាក់ ត្រីស័ព្ទ ពីលើក៏បាន ប្រើ ក្បៀស ពីក្រោមក៏បាន,

ឧទាហរណ៍:

ឈាន់មាត់ហ៊ឺះ ឬ-ហ៊ុះ, យំហ៊ឺៗ! ឬ-ហ៊ុៗ!, សត្វហ៊ីង ឬ- ហ៊ុង, ហ៊ឹកហ៊ាក់ ឬ ហ៊ុក-, ហ៊ឹងត្រចៀក ឬ ហ៊ុង-, ឈាន់មាត់ហ៊ឺះ ឬ-ហ៊ុះ, ប៉ឺរហ៊ឺៗ! ឬ-ហ៊ុៗ!

ជាដើម ។

តួ ស៊ី និង ហ៊ី កាលបើមានស្រៈ (ុំ) នេះប្រកប ផ្សំផង លោកបង្គាប់ឲ្យផ្លាស់ និគ្គហិត (ំ) នេះ ទៅជា "ម" វិញ (ផ្លាស់ ស៊ុំ ទៅជា ស៊ុម; ហ៊ុំ ទៅជា ហ៊ុម),

ឧទាហរណ៍:

ផ្លាស់ ស៊ុំ > ស៊ុម ដូចជា: ស៊ុមទ្វារ, ស៊ុមបង្អួច, ស៊ុមមាន់, ស៊ុមទា, ស៊ុមគ្រលុំ, ព្រៃស៊ុមទ្រុម;

ផ្លាស់ ហ៊ុំ > ហុម ដូចជាៈ ឈរហុមជិត, សំពត់ ផាហុម, ស្មោនហុមពាង, ទឹមានហុមហ, ស្អុយ ឈ្មោះហុម;

បើជាស្រៈ ( ុំ ) វិញ ចំពោះតួ “សំ” ត្រូវផ្លាស់ ត្រីស័ព្ទ ( ៊ ) នេះ ទៅជា ក្បៀស ( ុ ) ក្រោមវិញ,

ឧទាហរណ៍:

សុំបិត្ត, សុំគំនិត, សុំកម្លាំង, និយាយសុំ-ដែល ដូច្នេះជាដើម ។

ឃ) ចំពោះតួ អ៊ិ ទុកណាជាមាន ស្រៈ ឬ និគ្គហិត នៅពីលើក៏ដោយ ក៏មិនត្រូវប្រើ ក្បៀស ពីក្រោមឡើយ ត្រូវទុក ត្រីស័ព្ទ ( ៊ ) នេះ ឲ្យគង់នៅខាងលើដដែល,

ឧទាហរណ៍:

អ៊ី, អ៊ីកអ៊ាក, អ៊ីបិង, អ៊ីបុង, អ៊ីបុះ, អ៊ីបេះ, អ៊ីតើ, អ៊ិះអ៊ុះ, ក្របអ៊ីត ជាដើម ។

២.- ក្នុងពាក្យពីព្យាង្គ បើព្យាង្គខាងដើមជាហៃសៈ បង្អោនស័ព្ទទៅលើតួសំឡេងព្យាង្គខាងចុង ព្យាង្គខាងចុង មិនត្រូវប្រើ ត្រីស័ព្ទ (៊) នេះ ពីលើឡើយ,

ឧទាហរណ៍:

គុហា, ជំហរ, ជំហាន, ជំហាម, ជ្រហាម, ទាហាន, ទំហឹង, ទំហូ, ទំហំ, ទំហឹង, ទ្រហឹង, ត្រឹក-ត្រហាម, ព្រហូត, ព្រហើន, វិហារ, . . .

កុំសរសេរជា: គុហ៊ា, ជំហ៊រ, ជំហ៊ាន, ជំហ៊ាម ជ្រហ៊ាម, ទាហ៊ាន, ទំហ៊ឹង, ទំហ៊ូ, ទំហ៊ំ, ទំហ៊ឹង, ទ្រហ៊ឹង, ត្រឹកត្រហ៊ាម, ព្រហ៊ូត, ព្រហ៊ើន, វិហ៊ារ ដូច្នេះឡើយ;

## ៣) សំនួរ

ត្រីស័ព្ទ មានសណ្ឋានដូចម្ដេច? សម្រាប់ប្រើដាក់លើតួអក្សរណាខ្លះ? សម្រាប់ធ្វើសំឡេងអ្វីឲ្យទៅជាសំឡេងអ្វី?

ដូចឧទាហរណ៍ថា ម៉េចខ្លះ? កាលបើមាន ស្រៈនិស្ស័យ នៅពីលើនឹងផ្លាស់ ត្រីស័ព្ទ ទៅជាអ្វី? ផ្លាស់បានគ្រប់អក្សរទាំង៤តួឬ មានតួខ្លះផ្លាស់មិនបានដែរ? ចូរលើកឧទាហរណ៍មកពន្យល់? តួ ស៊ី នឹង ហ៊ី កាលបើមានស្រៈ ( ាំ ) នេះប្រកបផង លោកបង្គាប់ឲ្យផ្លាស់ និគ្គហិត ទៅជាអ្វី? ដូចឧទាហរណ៍ថា ម៉េច? ចំពោះពាក្យពីរព្យាង្គ បើព្យាង្គដើមមានសំឡេងជា ឃោសៈ បង្អោនផលទៅលើព្យាង្គខាងចុងតើព្យាង្គខាងចុងត្រូវដាក់ ត្រីស័ព្ទ ( ៉ ) នេះ ពីលើដែរឬទេ? ចូរលើកឧទាហរណ៍មកពន្យល់?

ការហាត់:

១.– ចូររកពាក្យដែលមានប្រើត្រីស័ព្ទ,

២.– ចូរស្រង់យកក្នុងបទខាងដើម ចំពោះពាក្យដែលមានស័ព្ទក្លាយពីស័ព្ទដើម, ហើយចូរពន្យល់តាមចំណាំវេយ្យាករណ៍;

១) ចម្លើយ

*

* *

## (៤) សំយោគសញ្ញា ( ័ )

វណ្ណយុត្តិនេះ ជាគ្រឿងសំគាល់នៃអក្សរតម្រួត ៗ ខ្មែរយកមកប្រើជាឈ្មោះវណ្ណយុត្តមួយបែប មានរូបយ៉ាងនេះ ( ័ ) ជាជំនួសអក្សរសំយោគ, សម្រាប់ប្រើដាក់លើពាក្យមគធៈ ឬ សំស្ក្រឹតពួកខ្លះ ដែលប្រើមកជាភាសាខ្មែរ ដើម្បីរក្សាលំនាំស្រៈ "អៈ" ឲ្យគង់នៅតាមសំនៀងដើម ផ្សំទៅនឹងតួប្រកប,

ឧទាហរណ៍៖

ក្សិណក្សយ > ក្សិណក្ស័យ, ជយ > ជ័យ, ទល > ទ័ល, ទោសក > ទោស័ក, នង្គល > នង្គ័ល, នយ > ន័យ, និស្សយ > និស្ស័យ, បច្ចយ > បច្ច័យ, ពិនយ > ពិន័យ, ព្រះទយ > ព្រះទ័យ, ភយ > ភ័យ, មធ្យត > មធ្យ័ត, រហស > រហ័ស, វយ > វ័យ, វិនយ > វិន័យ, សមយ > សម័យ, សង្សយ > សង្ស័យ, អធ្យាស្រយ > អធ្យាស្រ័យ, អនាមយ > អនាម័យ, អាលយ > អាល័យ, អាស្រយ > អាស្រ័យ, ឧបនិស្សយ > ឧប-និស្ស័យ ។ល។

នេះបើពាក្យដែលមានសំយោគស្រាប់ហើយ បើមិនដាក់សំយោគសញ្ញា ( ័ ) នេះផ្សំផងទេ នឹងនាំឲ្យពិបាកថា ដូច្នេះត្រូវប្រើសំយោគសញ្ញានេះថែមទៀតក៏មានខ្លះ,

ឧទាហរណ៍:

ប័ក្កប័ន, ទសកណ្ឋ, បល្ល័ង្ក, ប្រវ័ញ្ចន៍, ប្រប័ណ្ឌ, ព័ទ្ធព័ន្ធ, ពិទ័គ្ធ, ពិភ័ក្តិ, ព័ស្តុភារ, ព្រ័ត្រ, ភគវ័ន្ត, ភ័ព្វ ឬ ភ័ព្យ, ម្រ័ក្សណ៍, យសស័ក្តិ, យ័ន្ត ឬ យ័ន្ត្រ, ល័ក្ត ឬ ល័ខ, ល័ព្ធ, ពាក្យស័ត្យ, ស្ម័គ្រ, អ័ព្ទ, អនេកអ័គ្ឃ *ដូច្នេះជាដើម ។*

*សម្រាប់ប្រើភាសាខ្មែរសុទ្ធក៏មានខ្លះ,*

ឧទាហរណ៍:

ខ្វ័រ, ដ័រ, ញ៉័រ, ទទ័រ, ទូទ័រ, ទំព័រ, ភ្ជ័រ, ដើមសង្ឃ័រ, ដើមសំព័រ, ស្តាន់ធ័រ, ធំប៉ុង, ស្បូរប៉ុងៗ *ជាដើម ។*

*សម្រាប់ប្រើភាសាដទៃក៏មានខ្លះ,*

ឧទាហរណ៍:

កុងត្រូល័រ, កុងទ័រ, កូរ៉ិកទ័រ, គូល័រ ឌុកទ័រ, ឌីរ៉ិកទ័រ, ស្ញូប្យ័រ, ប្យាក់ទ័រ, អាំងស្ប៉ិកទ័រ *ជាដើម*

ឬ ប្រើស្រៈ (ើ) នឹងតួ រ ប្រកបផងក៏បាន, ដូចជា:

កុងត្រូលើរ, ស៊ុប៉ើរយើរ, គូវ៉ើរណើរ ... ជាដើម ;

## ៣) សំនួរ

សំយោគសញ្ញា មានទ្រង់ទ្រាយដូចអ្វី? សម្រាប់ប្រើជំនួសអក្សរអ្វី? ប្រើបានយ៉ាងណាខ្លះ? ប្រើដាក់បានលើពាក្យអ្វីខ្លះ? ចូរលើកឧទាហរណ៍មកពន្យល់?

ការហាត់ :

១.– ចូរស្រង់យកបទខាងលើនេះ ចំពោះពាក្យដែលមានប្រើសំយោគសញ្ញាតាមបទបញ្ជាខាងលើ,

២.– ចូររកពាក្យដែលមានប្រើសំយោគសញ្ញា គឺ ពាក្យបាលី, ពាក្យខ្មែរ នឹងពាក្យដែលយកពីភាសាដទៃមកប្រើ;

១) ចម្លើយ

*

* *

[៥] រេផ[១] (៌)

រេផ (ជើងអក្សរ រ ហៅដោយសទ្ទុត) គឺជាឈ្មោះវណ្ណយុត្តិមួយយ៉ាង ដែលខ្មែរប្រើតាមបែប បាលី សំស្ក្រឹត, មានរូបសណ្ឋានដូច្នេះ (្) ក្លាយរូបមកទៀតជាយ៉ាងនេះ (៌) គឺជាតួអក្សរ "រ" ពេញទី ប៉ុន្តែសរសេរក្លាយបន្តិចម្តងៗទៅ ក៏ទៅជាមានសណ្ឋានដូចខាងលើនេះឯង ។

(ក្នុងសិលាចារឹកខ្មែរបុរាណច្រើនប្រើ "រ" ពេញតួ សម្រាប់ប្រើដាក់លើអក្សរតួបុងដូចយ៉ាង: គ៌ភ ... ជាដើម

(១) ហៅថា "រេផៈ" ក៏បាន ។

ឲ្យអក្សរតួដើមបន្ទាប់នោះមានសូរសំឡេងញ៉រ, ប្រើចំពោះតែភាសាសំស្ក្រឹត ឬ សំស្ក្រឹតក្លាយ, ដូចជា: គ័ភ៌, ទក្ខិណាព័ត៌, ទុគ៌ត, ទុគ៌ម, ទុជ៌ន, ទុព៌ល, ទុយ៌ស, ធម៌, បព៌ត, បរិបូណ៌, បូព៌, បូណ៌, ព័ណ៌, ព្រះការណ៌, មគ៌ក, មាគ៌, វិសជ៌នីយ ឬ វិសគ៌ៈ, អយ៌, អជ៌ុន ឬ អជ៌ូន, អាប៌ ជាដើម; តែបើមាន ស្រៈ ដែលទើសនាំឲ្យពិបាកសរសេរនោះ ត្រូវដាក់អក្សរ "រ" ពេញតួពីលើដើមអក្សរខាងចុងវិញ,

ឧទាហរណ៍:

ទុរ្ភិក្ស, មូរ្តិ, រាមកេរ្តិ៍, កេរ្តិ៍ឈ្មោះ, តិរ្យ ជាដើម; ជួនកាលមិនមានស្រៈទើសទែងទេ ប៉ុន្តែគួរឲ្យប្រឡំពិបាកអាន ក៏ត្រូវដាក់តួ "រ" លើដើមអក្សរខាងចុងបានដែរ ដើម្បីឲ្យងាយមើលងាយអាន, ដូចជា: កមិ៌ន,

វិមិន៍, អស្វាយិ, អាបាយិ ប្រើជា: ក្សែន, វ្សែន, អស្វារ្យ, អាបារ្យ ជាដើម ។

បើមានអក្សរ "រ" ជាតួប្រកបពីខាងចុង នឹងប្រើរបាទ (៌) នេះផងពុំបានឡើយ, គេនឹងប្រើ សំយោគសញ្ញា (៍) នេះវិញ,

ឧទាហរណ៍:

ខ្ស័រ, ជ័រ, ញ័រ, ទទ័រ, ទូទ័រ, ទំព័រ, ភ្ល័រ, ដើមសង្ឃ័រ, ដើមសំព័រ, ស្ពាន់ធ័រ ជាដើម;

កុំប្រើជា: ខ្ស័រ៌, ជ័រ៌, ញ័រ៌, ទទ័រ៌, ទូទ័រ៌, ទំព័រ៌, ភ្ល័រ៌, ដើមសង្ឃ័រ៌, ដើមសំព័រ៌, ស្ពាន់ធ័រ៌ ដូច្នេះឡើយ ។

ក) សំនួរ

របាទ មានទ្រង់ទ្រាយដូចម្តេចខ្លះ? សម្រាប់ប្រើយ៉ាងណាខ្លះចំពោះពាក្យបាលីនឹងពាក្យសំស្ក្រឹត? ចូរលើកឧទាហរណ៍មកពន្យល់? បើមានអក្សរ "រ" ជាតួប្រកប

នៅខាងចុង ទឹងប្រើ របាទ (៌) នេះផងបានឬទេ? ប្រើ ដាក់ក្នុងពាក្យខ្មែរដូចឧទាហរណ៍ថាម៉េច?

ការហាត់ :

១.– ចូររកពាក្យដែលមានប្រើរបាទ,

២.– ចូររើសយកពាក្យដែលត្រូវដាក់តួ "៌" លើជើងអក្សរខាងចុង;

១] ចម្លើយ

| |
|---|
| |

*

* *

## (៦) បដិសេធ[១] (៤)

វណ្ណយុត្តិមួយបែប មានរូបសណ្ឋានដូចកន្ទុយកំប្រុក

(១) ហៅថា "ទណ្ឌឃាត" ក៏បាន ។

យ៉ាងនេះ (៍) សម្រាប់ប្រើដាក់ឃាត់អក្សរដែលជាប់មកពី បាលី ឬ សំស្ក្រឹតពួកខ្លះ មិនឲ្យមានសំឡេង,

ឧទាហរណ៍:

កិរិយាវិសេសន៍, ក្សត្រិយ៍, ខែស្រាពណ៍, ខែប្យារ៍, ប័ន្ទ៍ស, ប័ន្ទ៍ក្រហម, គមនាគមន៍, គោពាទ៍, គ្រាហ៍មនុស្សឈើ, ត្រៃគម្ពាសន៍, ជល-ន័យន៍ ឬ-នេត្រ, ដើមអាសន៍, ព្រះត្រៃលក្ខណ៍ ឬ-លក្សណ៍, ត្រៃរតន៍ ឬ-រត្ន, ប៉ៃសៅរ៍, ទុឧប្បាសន៍, ទាស់ការណ៍, ទេសបរណ៍, ទោសពៃរ៍, នាវាចរ-ណ៍, នេសាទុបករណ៍, បដិវត្តន៍, បរិវត្តន៍, បាដិ-ហារិយ៍, បាយសិង្ឃាតក៍, បារាយណ៍, បៀរត្សរ៍, ប្រណិប័តន៍, ប្រយោជន៍, ប្រសាសន៍, ប្រាង្គណ៍, ពាក្យពេចន៍, ពិសោធន៍, ពុទ្ធសាសន៍, ព្រាហ្មណ៍,

ព្រឹត្តិការណ៍, ព្រះជីវ៍, ព្រះពៃស្រពណ៍, ព្យាករណ៍,
ភាជន៍, ភេរីបរណ៍, មរណ៍, មគ្គទេសន៍ ឬ មគ្គុ-
ទ្ទេសន៍, មហាជាតក៍, មានពក៍, មិគព័ន្ធន៍, សមុហ៍,
មុខភាហ៍, មុនីសាភារណ៍, មោហ៍បាំង, ម្រ័ក្សណ៍,
យុទ្ធោបករណ៍, យោជន៍, រាជនិវេសន៍, រាហុចាប់
ប័ន្ទ្រ, រហ៍ពល, លក្ខណ៍ ឬ លក្សណ៍, វិឡ្សន៍,
វេយ្យាករណ៍, វេហាស៍, សតវត្សរ៍, សប្តប្រករណ៍,
សិល្ប៍, សុខវិឡ្សន៍, សុបីនយ៍, សុមេរ៍, សេយ្យាសន៍,
ស្នេហ៍, អធិករណ៍, អនុវត្តន៍, អភិនេស្រ្កមណ៍,
អភិរូហ៍, អភិវន្ទន៍, អលង្ករណ៍, អស្តង្គមន៍,
អស្សុពាហ៍, អាពាហ៍ពិពាហ៍, អាគ្នេយ៍, ឧទ្ធរណ៍,
ឧទាហរណ៍, ឧបករណ៍, ឧបជ្ឈាយ៍, ឧបាទវ៍,
ឧស្សាហ៍ ជាដើម ។

ពាក្យខ្មែរសុទ្ធក៏មានយកបដិសេធ(៌)នេះមកប្រើខ្លះ ដែរ គឺប្រើតាមសំដីសាមញ្ញឬពាក្យផ្សារឬក្នុងពាក្យកាព្យ,

ឧទាហរណ៍:

មក៌ពីណា ; មក៌ពីអង្កាល់ៗ; នែ៍ ម៉ែវាអើយ មើល៌វាផង, ប្រយ័ត្នវាវារធ្លាក់ដីណា៎ះ!; អើ៍ បើ ឃើញវាមក៏ វាប់រក៏វាផងៗ... ។

ខាងភាសាសំស្ក្រឹត, កាលបើមានបដិសេធ(៌)នេះ នៅពីលើតួអក្សរណា តួអក្សរនោះលោកទុកជាតួប្រកប គ្រាន់តែមិនបញ្ចេញសំឡេងប៉ុណ្ណោះឯង,

ឧទាហរណ៍:

កម៌, វម៌, តបស៌, តេជស៌, អាត្ម៌,

(ត្រូវអានថា: ក្រម៌, វ្រម៌, តៈបុស, តេជ៌ស, អាត្ម៌) ជាដើម, ដូចដែលហៅតាមភាសាសំស្ក្រឹតថា: វិរាម មានរូបដូច្នេះ (^) សម្រាប់ប្រើដាក់ពីក្រោមតួ

អក្សរទេវនាគរី ឃាត់មិនឲ្យបញ្ចេញសំឡេង ឲ្យគ្រាន់តែជាតួប្រកប, ដូចជា: កម៌ន៑, វម៌ន៑, តបស៑, តេជស៑, អាត្មន៑ ជាដើម (ក្នុងវេយ្យាករណ៍សំស្ក្រឹតខ្មែរ លោកប្រើវណ្ណយុត្តិដូច្នេះ (—) ជំនួស (^) នេះវិញ, ដូចជា: តបស៑ ជាដើម) ។

សម្រាប់ប្រើភាសាដទៃក៏មានខ្លះ, ដូចជា: ស៊ីម៉ង់ត៍, ប្រេស៊ីដង់ត៍, អាល់ប៊ែរត៍, ទីប៉េត៍, ឡូត៍, ដឺក្រូ-ពង់ត៍, . . . ជាដើម ។

គ) សំនួរ

បដិសេធ ឬ ទណ្ឌឃាត មានទ្រង់ទ្រាយដូចអ្វី? សម្រាប់ប្រើយ៉ាងណាខ្លះក្នុងពាក្យបាលីនិងពាក្យសំស្ក្រឹត? ក្នុងពាក្យខ្មែរសុទ្ធមានប្រើឬទេ? ចូរលើកឧទាហរណ៍មកពន្យល់,

ការហាត់:

ចូររកពាក្យដែលមានប្រើទណ្ឌឃាត;

១) ចម្លើយ

| |
|---|
| |

*

* *

## (៧) លេខអស្ដា (៨)

វណ្ណយុត្តិមួយបែប មានរូបសណ្ឋានជាលេខប្រាំបីយ៉ាងនេះ (៨) សម្រាប់ប្រើដាក់លើអក្សរទោល នាំអក្សរនោះឲ្យមានសំឡេងកញ្ចក់ខ្លីរហ័ស, ច្រើនប្រើដាក់លើអក្សរ ៤ តួគឺ: ក, ដ, ន, ហ;

១) ប្រើដាក់លើតួ ក៏, ដូចជា: ក៏គង់តែ, ក៏ទេដែរ, ក៏ទៅ, ក៏មក, ក៏ដោយ, ក៏មាន, ក៏បាន ជាដើម;

២) ប្រើដាក់ពីក្រោយ ដ៏, ដូចជា: ដ៏បវរ, ដ៏ប្រសើរ, ដ៏ប្រពៃ ដ៏មាន, ដ៏វិចិត្រ, ដ៏ហើយដោយ..., ដ៏ឧត្តម, ព្រះដ៏មានព្រះភាគ ជាដើម;

៣) ប្រើដាក់ពីក្រោយ ន៏, ដូចជា: ន៏!, ធុះន៏!, ឯណេះន៏!, ន៏មើលបុះ!, អញន៏! ជាដើម;

៤) ប្រើដាក់ពីក្រោយ ហ៏, ដូចជា: ហ៏!, ហ៏!យកបុះ, បើធ្វើមិនកើតគ្រាន់តែទៅជួយបោះហ៏នឹងគេក៏បានហើយ! ។

កាកបាទ

លេខអស្ដា មានទ្រង់ទ្រាយជាលេខប្រាំបីយ៉ាងនេះ (៨) ឯ ទណ្ឌឃាត ឬ បដិសេធ មានរូបសណ្ឋានដូចកន្ទុយកង្កែបយ៉ាងនេះ (៍) ។

ក) សំនួរ

លេខអស្តា មានទ្រង់ទ្រាយដូចអ្វី? សម្រាប់ប្រើយ៉ាងម៉េចខ្លះ? ដាក់បានលើអក្សរណាខ្លះ? ចូរលើកឧទាហរណ៍មកពន្យល់ផង?

ការហាត់៖

ចូររើសរកពាក្យដែលមានប្រើទណ្ឌឃាត៖

១) ចម្លើយ

* * *

## (៨) វិសជ្ជនីយ[១] (ះ)

វណ្ណយុត្តិមួយបែបមានសណ្ឋានជារង្វង់មូលពីរទន្ទឹម

(១) ហៅថា "រះគិះ ឬ រះមុខ" ក៏បាន ។

គ្នាយ៉ាងនេះ (ះ) មានសូរសំឡេងស្រដៀងនឹងខ្យល់អក្សរ "ស់" ដែលជាតួប្រកប, ប៉ុន្តែមិនចេញសូរសម្លស្រតាម ប្រទល់ឈ្មោញដូចតួ "ស់" ទេ ជាសំឡេងកំបុតខ្លី,

ឧទាហរណ៍:

"កែះ, កន្លះ, ខ្វះ, ប៉េះ, ជុះ, ញោះ, ពោះ" ពាក្យទាំងនេះ មានសូរសំឡេងខុសគ្នានឹងពាក្យថា: "កែស, កន្លាស់, ខ្វាស, ប៉េស, ជុស, ញោស, ពស់" ជាដើម ។

វិសជ្ជនីយ (ះ) នេះ យកទៅប្រើប្រកបនឹងស្រៈនិស្ស័យបាន ១២ តួ គឺ: ា, –ា, –ិ, –ី, –ឹ, –ឺ, –ុ, –ើ, េ–ៀ, េ–, ែ–, េ–ា;

១) ប្រើប្រកបនឹងស្រៈ (ា), ដូចជា: ទះ, គះ, ត្របះ, ជិះ, ឈ្នះ, បំណោះ, តេះតះ, ធះ, ផ្ទះ, ឥឥះ-, បះ, ផ្ទុះ, សំពះ, ព្រះ, ម្នះ, យះ, វះ, លះ, រះ, សះ, អះ- ជាដើម;

២) ប្រើប្រកបនឹងស្រៈ (-ា), ដូចជាៈ ឆ្លើយ ប៉ាះ!, អ៉ាះ! ឈឺណាស់ ជាដើម;

៣) ប្រើប្រកបនឹងស្រៈ (ិ) ដូចជាៈ ខ្ញិះ, សំគិះ, ងងិះ, ជិះ, តំណិះ, តម្រិះ, ត្រិះរិះ, តិះដៀល, ជិគិះ, រិះ, ជ្រិលិះ, រិះ, អិះអុិះ ជាដើម;

៤) ប្រើប្រកបនឹងស្រៈ (ឺ) ដូចជាៈ យឺះ! ពស់ធំណាស់, យឺះ! មកពីអង្កាល់?, យឺះ! ខ្មោចលង ជាដើម;

៥) ប្រើប្រកបនឹងស្រៈ (ឹ) ដូចជាៈ កឹះគ្នា, ឮសើបយឹះ, ឆ្កឹះ, អំណឹះ, ទង្គឹះ, ធ្វើការមឹះ, ប្អឹះ ប្ដុព្អឹះ, មឹះៗកែះឆ្នាំងបាយធ្លុះ, រលឹមប្រឹះៗ, ខែប្រាំង ពាំងរឹះ, បោលរឹះត្រូវ, លាត់មាត់ហឹះ!, ទុកជាស្ដី បន្ទោសយ៉ាងណាក៏មិនអឹះ, ខឹងអឹះអ៊ឹះទះកន្ទេល, អារឹះកូន ជាដើម;

៦) ប្រើប្រកបនឹងស្រៈ (ឹ), ដូចជា: ទង្គឹប-ក្បាលទឹះ, ដកកឹះ, ប៉ឹះៗ!, អាប៊ឹះ, អ៊ឹះបង!, ឆ្ងើយអ៊ឹះ!, ឆ្ងើយវ៊ឹះ! ជាដើម;

៧) ប្រើប្រកបនឹងស្រៈ (ុ), ដូចជា: កុះ, ខ្ទុះ, បុះ, ង្ហុះ, ជុះ, ញុះ, ដុះ, តុះ, រទុះ, ផ្ទុះ, ស្ទុះ, បុះ, ផ្លុះ, ពុះ, យុះៗ!, រុះ, លុះ, ស្លុះ, សើបហ៊ុះៗ!, អេះអុះ ជាដើម;

៨) ប្រើប្រកបនឹងស្រៈ (ើ), ដូចជា: បង្កើះ, ង្កើះ, អំណើះ ជាដើម;

៩) ប្រើប្រកបនឹងស្រៈ (ៀ), ដូចជា: វៀះវៀង (ម. ព. វេះវៀង);

១០) ប្រើប្រកបនឹងស្រៈ (េ). ដូចជា: ប៉េះ. ឆេះ, បំណោះ, រទេះ, គេះ, វេះ, សេះ, អេះ ជាដើម;

១១) ប្រើប្រកបនឹងស្រៈ (ែ–), ដូចជា: កែះ, ខ្វែះ, បំបែះភ្នំ, បំអែះ, ប្រែះ, ឆ្អែះ, កញ្ចែះប្រក, គោបាស្នាតែះ, ត្រែះ, សំទែះ, ពភ្លែះ, សួរផ្ទុះ ប្រែះៗ, ឆែះ, ស្លែះទុកសិត, ស្រែះ, ឮសើប បែះៗ! ជាដើម;

១២) ប្រើប្រកបនឹងស្រៈ (ោ–), ដូចជា: កោះ, គោះ, ឃ្មោះ, បោះ, ឆ្ពោះ, ឈ្មោះ, ទោះ, ដោះ, ប៉ោះ, ពោះ, ភ្លោះ, មោះ, ពីរោះ, លោះ, សោះ, ហោះ, អ៊ោះអ៊ោ! ជាដើម ។

ពាក្យសំស្ក្រឹតប្រើមកជាខ្មែរដែលមានតួ " ហ " ប្រកបនៅខាងចុង ត្រូវផ្លាស់តួ " ហ " ជា វិសជ្ជនីយ (ះ) នេះវិញ,

ឧទាហរណ៍៖

គ្ឫហ > គ្ឫះ ឬ គ្រឹះ, បន្ទ្រាហ > បន្ទ្រោះ, សំគ្រហ > សង្គ្រោះ, អនុគ្រហ > អនុគ្រោះ ។ល។

> កុំសរសេរជា៖ គ្រឹះហ៍, បន្ទ្រោះហ៍, សង្គ្រោះហ៍, អនុគ្រោះហ៍ ដូច្នេះឡើយ ។

## ក) សំណួរ

វិសជ្ជនីយ មានទ្រង់ទ្រាយដូចម្ដេច? មានសូរសំឡេងស្រដៀងនឹងខ្យល់អក្សរអ្វី? មានបញ្ចេញសំឡេងតាមប្រទេសផ្សេងឬទេ? សម្រាប់ប្រើប្រកបនឹង ស្រៈ បាន ប៉ុន្មានតួ? ស្រៈ អ្វីខ្លះ? ចូរលើកឧទាហរណ៍មកពន្យល់គ្រប់ស្រៈទាំងអស់មើល? ពាក្យសំស្ក្រឹតប្រើមកជាខ្មែរ ដែលមានតួ "ហ" ប្រកបនៅខាងចុង ត្រូវផ្លាស់ "ហ" ទៅជាអ្វីវិញ? ចូរលើកឧទាហរណ៍មកមើល?

ការហាត់:

ចូររកពាក្យដែលមានប្រើវិសជ្ជនីយ;

១) ចម្លើយ

*

* *

## (៩) យុគលពិន្ទុ[១] (:)

វណ្ណយុត្តិមួយបែបមានសណ្ឋានជាចំណុចពីរទន្ទឹមគ្នា យ៉ាងនេះ (:) ដូចគ្នានឹងដីក្យពង់តបារាំង) Deux points), សម្រាប់ប្រើចុចពីខាងមុខពាក្យបាលី ឬ សំស្រ្កឹតដែលមានសំឡេងកើតអំពីស្រៈ "អ:" ឲ្យមានសំឡេងនៅពេញមាត្រាជាបាលី ឬ ជាសំស្រ្កឹតដដែល (កុំឲ្យប្រែទៅនឹង

(១) យុគលពិន្ទុ ន. (ម. យុគល "គូ" + វិន្ទុ ឬ ពិន្ទុ "ដំណក់, ចំណុច") ប្រែថា: «ចំណុចមួយគូ ឬ ចំណុចពីរទន្ទឹមគ្នា» ។

ពាក្យបាលី ឬ ពាក្យសំស្រ្កឹតក្លាយ ដែលអានទោលស្រះ "អះ" មិនពេញមាត្រា),

ឧទាហរណ៍:

ខេមរះ, គារវះ, ឃោសះ, ឆន្ទះ, ជីវះ, តបះ, ឋាវរះ, ទណ្ឌះ, ទន្តជះ, ទស្សនះ, ទាសះ, ទីឃះ, វស្សះ, ទោសះ, ធុរះ, បដិសណ្ឋារះ, ពលះ, ព្យញ្ជនះ, ភណ្ឌះ, ភារះ, ភេសជ្ជះ, មរណះ, មុទ្ធជះ, មោហះ, លក្ខណះ, លេខ-អត្ថះ, វិបឥះ, វណ្ណះ, វីរិយះ, សក្ការះ, សង្គហះ, សភាវះ, សមណះ, សរីរះ, សាធារណះ, សីហះ, សុខះ, ស្រះ, អក្ខរះ, អឃោសះ, អរិយះ, ឥស្សរះ ជាដើម ។

សម្រាប់ប្រើចុចពីខាងមុខពាក្យខ្មែរសុទ្ធ ដែលមានសំឡេងកើតអំពីស្រះ អះ, អាះ, អេះ ក៏មានខ្លះ,

ឧទាហរណ៍:

រយៈ, ភិរៈ, កាលៈទេសៈ, វ៉ឺមរ៉ៈ! ឬ វ៉ឺមរ៉ៈអឺ!, ដំណោះទេហ្ន:?, មាតាបិតាត្រូវសង្គ្រោះបុត្រធីតាដោយស្មានប៉ុន្មានយ៉ាងហ្នះអ្នក? ។ ហ៊ាះ, អឺហ៊ាះ, អញហ៊ាមែនៗហ៊ាះ, ឯងហ៊ាមិនឲ្យគ្នាទៅអឺហ៊ាះ បានជាគ្នាមិនទៅ!, អ្ហះ! កុំធ្វើខុសទេ!, អ្ហះ! កុំកាន់ប្រយ័ត្នដួល! ។ ស្រែកយ៉េះយ៉ុ, និយាយអេះអុ, និយាយរអេះរអុស្ដាប់មិនបាន, អ្ហេះ! ឬ ហោះ! ឈប់សិន, អេះអុៗនិយាយមិនរួច ។ល។

ពាក្យណាដែលជា បទសមាស ឬជាសមាស-នាម លោកហាមមិនឲ្យប្រើ យុគលពិន្ទុ (:) នេះនៅចំពាក់កណ្ដាលព្យាង្គឡើយ,

ឧទាហរណ៍:

កម្ពុជរដ្ឋ, ខេមរជាតិ, ខេមរភាសា, មគធ-

ភាសា, មរណភាព, មរណទុក្ខ, មរណកាល, មរណសញ្ញា, រាជបុត្រ, រាជបរិពារ ឬ — វារ, សក្ការបូជា, សាធារណការ, សាធារណនាម, សេនាសនទាន, អក្ខរវិធី, ឥស្សរជន, ឥស្សរភាព, សមភាព, ភាតរភាព ជាដើម;

កុំប្រើចុចកណ្ដាលជា. កម្ពុជរដ្ឋ, ខេមរៈជាតិ, ខេមរៈភាសា, មគធៈភាសា, មរណៈភាព, មរណៈ-ទុក្ខ, មរណៈកាល, មរណៈសញ្ញា, រាជៈបុត្រ, រាជៈ-បរិពារ ឬ — វារ, សក្ការៈបូជា, សាធារណៈការ, សាធារណៈនាម, សេនាសនៈទាន, អក្ខរៈវិធី, ឥស្សរៈជន, ឥស្សរៈភាព, សមៈភាព, ភាតរៈភាព

តែបើមានពាក្យដែលមិនមែនជា បទសមាស ជាពាក្យដែលមានព្យាង្គដោយឡែកពីគ្នា នោះលោកបង្គាប់ឲ្យប្រើចុចកណ្ដាល, ដូចជា: សម្ដេចព្រះសង្ឃនាយកទាំងពីរគណៈ, គណៈមហានិកាយ, គណៈធម្មយុត្តិ, គណៈរដ្ឋមន្ត្រី, គណៈប្រតិភូ, គណៈកម្មការវិប្បធម៌, គណៈកម្មការអន្តរជាតិ, គណៈកម្មការវត្ត, គណៈបក្ខ ឬ- បក្ស ។ល។

មួយទៀត, យុគលពិន្ទុ (:) នេះ មិនមានសំឡេងទេ, សម្រាប់ប្រើជាសញ្ញាជាកជាគ្រឿងសំគាល់ការបន្ថែមពាក្យ ឬ បន្ថែមសេចក្ដីខាងមុខ ដែលជាឧទាហរណ៍ ឬជាកំស្ដាន់ជាដើម,

ឧទាហរណ៍:

ឪពុកនិយាយទៅកាន់កូនថា: «ប្ដីកូនឯងខំប្រឹងប្រែងរៀនសូត្រទៅទាន់ខ្លួននៅក្មេងណាះកូនណា!»;

ឬប្រើចុចពីមុខមេពាក្យ, ដូចជា:

វិបសាធិប្បាយ: . . . . . . . . . ;

អក្ខរាវិរុទ្ធ: . . . . . . . . . . ;

ការហាត់: . . . . . . . . . . . . . ;

ពន្យល់ពាក្យ: . . . . . . . . . ;

ពាក្យត្រូវរៀន: . . . . . . . . . . ;

នាម: . . . . . . . . . . . . ;

គុណនាម: . . . . . . . . . . ;

កិរិយាសព្ទ: . . . . . . . . . . ;

បើប្រើក្នុងក្បួនគណិតសាស្ត្រ, យកុគលពិន្ទុ(:)នេះ ប្រែថា "ចែកនឹង" ជាសញ្ញាសម្រាប់សំគាល់ថាត្រូវរក ចំណែក ឬ ភាគដែលត្រូវចែក, ឧទាហរណ៍: ៤:២ = ២ ។

កុំច្រឡំ:

ប៉ុន្តែយុគលពិន្ទុ មានសណ្ឋានជាចំណុចពីរដូចេះ(:),

៦ វិសជ្ជនីយ មានសណ្ឋានជារង្វង់មូលពីរទន្ទឹមគ្នាយ៉ាង

នេះ (ះ) ។

ក) សំនួរ

យុគលពិន្ទុ មានទ្រង់ទ្រាយដូចម្តេច? សម្រាប់ប្រើ

ដូចម្តេចខ្លះក្នុងពាក្យបាលី នឹង ពាក្យសំស្ក្រឹត? ពាក្យខ្មែរ

សុទ្ធមានប្រើ យុគលពិន្ទុ នេះឬទេ? ពាក្យដូចម្តេចដែល

លោកហាមមិនឲ្យប្រើ យុគលពិន្ទុ? យុគលពិន្ទុ នេះ

មានន័យបង្គាប់ឲ្យប្រើយ៉ាងណាខ្លះទៀត? ចូរនាំឧទាហរណ៍

មកពន្យល់ឲ្យល្អមស្តាប់បាន?

ការបាត់:

ចូរស្រង់យកពាក្យបាលី, ពាក្យសំស្ក្រឹតឬពាក្យខ្មែរ

សុទ្ធដែលមានប្រើយុគលពិន្ទុនេះ;

១) ចម្លើយ

* * *

\+ + + + + + + + + + + + + + + + + + + + + + + + + + +

\+ + + + + + + + + + + + + + + + + + + + + + + + + +

## (១០) គាកបាទ[១] (+)

វណ្ណយុត្តិមួយបែបមានរូបស្រដៀងនឹងក្រញ៉ាំជើងក្អែក យ៉ាងនេះ (+) សម្រាប់ប្រើទាញសំឡេងអក្សរឱ្យខ្ពស់ជាងប្រក្រតីដើម,

ឧទាហរណ៍:

ឆ្អើយ៎ក្លុក!; ឆ្អើយប៉ាះ៎!; សុំឱ្យក្លូនជាទៅណា៎ះ គាងណា៎! ឬប្រើជា "ហ្ន៎ះ ហ្នា៎!" យ៉ាងនេះក៏បាន; អុ៎ះ; អុ៎ះអឺ!; អុ៎ះឯង; អ៊ឺហ្ន៎!; អា៎ះ! ល្អណាស់ហ្ន៎!; អ្ហ៎!

(១) ហៅថា "ជើងក្អែក" ក៏បាន ។

ឯណោះទេឬ?; អ្ហា! កុំមិនបានទេ!; អ្ហាះ! ឋាម៉េច?; អ្ហ! យល់ហើយ!; អ្ហុះ! លឿនណាស់វ៉ុ!; អ្ហា! ដល់ណោះហើយ!; អ្ហោះ! ឃាញគេហើយ; អ្ហុះ! នៅឯណារកមិនឃើញ? ។ល។

*សម្រាប់ប្រើទៀតអក្សរដែលសរសេរគេច ហើយសរសេរទៀតបន្ថែមពីលើ ឬពីក្រោម,*

ឧទាហរណ៍:

នេះគឺច្បាប់ក្រម ប្រូសើ៍ឧត្ដម ទូនានអ្នកផង... ។

*សម័យឥឡូវ មានប្រើគំនូស (‾∨‾) នេះ ជំនួសកាកបាទ (+) នេះ ក៏មានខ្លះ,*

ឧទាហរណ៍:

ប្រើឱសំ ទោន កុំបមានគ្គង .......។

កាកបាទ (+) នេះ ប្រើបានទៀត សម្រាប់សំគាល់ពាក្យថា "នឹង" ឬ "ហើយនឹង",

ឧទាហរណ៍:

ត្រៃយមាទិ < ត្រៃ + អយំ + អាទិ (អានថា ត្រៃយមាទិ មកពី ត្រៃ នឹង អយំ នឹង អាទិ) ត្រៃ + អយំ + អាទិ > ត្រៃយមាទិ ។

= អាសន្នអន្តក្រ (អានថា អាសន់-អន់-ក្រ) អាសន្ន "ជិត" + អន្ត "ផង់ត, ខ្វាក់" + ក្រ > អាសន្នអន្តក្រ ។

សម្រាប់ប្រើលេខបូកកង់ក្បួនពន្ធក៏មាន, ដូចជា:

១ + ២ = ៣ ។ ៣ + ៤ = ៧ ។ ៧ + ៣ = ១០ ។

## គ) សំនួរ

កាកបាទ មានសណ្ឋានដូចម្ដេច? សម្រាប់ប្រើបានយ៉ាងណាខ្លះ? ចូរលើកឧទាហរណ៍មកពន្យល់ផង?

ខ) ចម្លើយ

* *
*

ៗ ៗ ៗ ៗ ៗ ៗ ៗ ៗ ៗ ៗ ៗ ៗ ៗ ៗ ៗ ៗ ៗ ៗ ៗ ៗ

ជ ជ ជ ជ ជ ជ ជ ជ ជ ជ ជ ជ ជ ជ ជ ជ ជ ជ ជ ជ

## (១១) លេខទោ[១] (ៗ)

វណ្ណយុត្តិមួយបែបមានសណ្ឋានខាងក្បាលដូចលេខ២ ប៉ុន្តែកន្ទុយយោរចុះក្រោមផុងបន្តិចយ៉ាងនេះ (ៗ) សម្រាប់សរសេរខាងមុខពាក្យដែលត្រូវថាផ្ទួនពីរដង, ដែលថា ដដែលៗ ដែលថាផ្ទួនៗ (ប្រើចំពោះតែសំដី),

ឧទាហរណ៍:

ក្មេងៗ, ចាស់ៗ, ដដែលៗ, ទីទៃៗ, តូចៗ,

(១) ហៅថា "អាមេណ្ឌិតសញ្ញា" ក៏បាន ។

ធំៗ, វេង្វងៗ, ភ្លរៗ, ប្រហែលៗគ្នា, ដូចៗគ្នា, កំទេ្លាះៗ, ក្រមុំៗ, តាៗ, យាយៗ ជាដើម ។

*ពាក្យបាលីយកមកប្រើជាខ្មែរ ទុកណាជាពាក្យផ្ទួនគ្នា កំមិនត្រូវយក លេខទោ (ៗ) នេះ មកប្រើពីមុខឡើយ,*

ឧទាហរណ៍:

នានាធម្មសំវេគ; នានាជាតក; វិវិធធម្ម-សង្គហ; វិវិធភណ្ឌ; អាបោអាបោ; ដំណាំង នានាប្រទេស; មន្ត្រីនានា;

*មិនត្រូវសរសេរជា:* នាៗធម្មសំវេគ; នាៗ-ជាតក; វិៗធធម្មសង្គហ; វិៗធភណ្ឌ; អាបោៗ; ដំណាំងនាៗប្រទេស; មន្ត្រីនាៗ *ដូច្នេះឡើយ ។*

ត) សំនួរ

លេខទោ ម្ត អាមេណ្ឌិតសញ្ញា មានទ្រង់ទ្រាយ

ដូចម្ដេច? សម្រាប់ប្រើយ៉ាងណា ខ្លះក្នុងការសរសេរ? លេខទោ ប្រើបានចំពោះតែពាក្យខ្មែរសុទ្ធឬ? ពាក្យបាលី ប្រើលេខទោបានដែរឬទេ? ចូរលើកឧទាហរណ៍មកពន្យល់?

ការហាត់:

ចូរស្រង់យកពាក្យដែលមានប្រើលេខទោ;

១) ចម្លើយ

* *

*

ចប់វិធីប្រើវណ្ណយុត្តិ

# វិធីប្រើខណ្ឌសញ្ញា

◎ ◎ ◎ ◎ ◎ ◎ ◎ ◎ ◎ ◎ ◎ ◎ ◎ ◎ ◎
◎ ◎ ◎ ◎ ◎ ◎ ◎ ◎ ◎ ◎ ◎ ◎ ◎ ◎

## (១) ភ្នែកមាន់[១] (◎)

ខណ្ឌសញ្ញាមួយបែបមានសណ្ឋានជាវង់មូលពីរជាន់ តូចក្នុងធំក្រៅ ស្រដៀងនឹងភ្នែកមាន់យ៉ាងនេះ (◎) សម្រាប់ប្រើដាក់ក្បាលបន្ទាត់ ដើមសេចក្ដីធំនីមួយៗ ឬប្រើដាក់នៅខាងដើមបទ ក្នុងពាក្យកាព្យឃ្លោង,

ឧទាហរណ៍:

◎ ជុលីហត្ថនមស្ការដាក់លើកេស តាង
ប្រទីបកោសុមបុទមទេស បិត្តវិសេសបង្គំបាទព្រះ
សាស្ដា . . . . . . ។

---

(១) ហៅថា "កុក្កុដនេត្រ" ក៏បាន ។

ក្នុងពាក្យធម្មតា (នាបុរាណសម័យ) លោកច្រើនប្រើ ភ្នែកមាន់ (៙) នេះ នៅដើមលិខិត ឬ រឿងរ៉ាវផ្សេងៗ ជាគូគ្នានឹង គោមូត្រ (៚—) នេះ ដែលលោកដាក់បញ្ចប់លិខិត ឬ រឿងរ៉ាវផ្សេងៗ ។

(សព្វថ្ងៃនេះ នៅក្នុងពាក្យរាយលោកមិនសូវប្រើទេ)

ក) សំណួរ

កុក្កុដនេត្រ ឬ ភ្នែកមាន់ មានទ្រង់ទ្រាយដូចម្ដេច? សម្រាប់ប្រើយ៉ាងណាខ្លះ? ចូរលើកឧទាហរណ៍មកពន្យល់? សព្វថ្ងៃនេះគេនៅនិយមប្រើដែរឬទេ?

ខ) ចម្លើយ

* *
*

## (២) ខណ្ឌ ឬ ល្បះ (១)

ខណ្ឌសញ្ញាមួយបែបមានរូបយ៉ាងនេះ (១) សម្រាប់ប្រើផាកពាំងឃ្លា ឬ សង្កាត់សេចក្ដីមួយ ៗ ឲ្យដាច់ស្រឡះដោយឡែកពីគ្នា,

ប្រើបាន ៣ យ៉ាង គឺ:

ក) ល្បះដែលប្រើខណ្ឌសេចក្ដីខ្លីឬសេចក្ដីវែង, ដូចជា:

ប្រាសាទនាគព័ន្ធ មានកំពែងខាងក្រៅប្រវែង ៣៥០ ម៉ែត្របួនជ្រុងស្មើ ៗ នៅខាងក្នុងកំពែងមានស្រះធំៗបួនជ្រុងស្មើ នៅគ្រប់ទិសទាំង ៤ ។ តពីនោះមាន . . . . . . . . . ។

ល្បះដែលប្រើខណ្ឌសេចក្ដីខ្លី ឬ សេចក្ដីវែងដូចឧទាហរណ៍ខាងលើនេះលោកហៅថា "ល្បះតូច ឬ ល្បះធំ"។

ខ) ល្បះដែលប្រើខ័ណ្ឌសេចក្ដីមួយវែងខាងលើហើយ ដែលត្រូវចាប់សរសេរបន្ទាត់មួយខាងក្រោមបន្ទាត់នោះ លូកចូលមកខាងក្នុងបន្តិច,

ឧទាហរណ៍:

ប្រាសាទនាគព័ន្ធ ស្ថិតនៅលើភ្នំនាគពីរ ដែលមានរង្វង់មូលធំ; កន្ទុយនាគទាំងគូរបររួម ព័ន្ធព័ទ្ធគ្នាជួបជាគេត្របាញ់ឡើងលើ ទៅទិសខាងលិច, ក្បាលទៅទិសខាងកើត ។

ប្រាសាទនេះ បែរមុខឆ្ពោះទៅទិសខាងកើត, (ព្រះបាទជ័យវរ្ម័នទី ៧ (Jayavarman VII) ទ្រង់ឱ្យកសាងក្នុងបុងសតវត្សរ៍ទី ១៨នៃពុទ្ធសករាជ...) ;

យ៉ាងនេះហៅថា "ល្បះបន្ទាត់ ឬ ល្បះលូកបន្ទាត់" ។

ក) ល្បះនេះមានប្រើទៀត ក្នុងការកត់ត្រាថ្ងៃខែឆ្នាំបន្តគ្នា,

ឧទាហរណ៍៖

ភ្នំពេញ, នៅថ្ងៃ ១ ᧠ ៥ ឆ្នាំមមែសប្ដស័ក
១០

ព. ស. ២៤៩៨ ។

(លេខខាងដើមល្បះជាលេខថ្ងៃ, លេខខាងចុងល្បះជាលេខខែ, លេខខាងលើល្បះជាលេខសម្រាប់ប្រាប់ខ្នើត, លេខខាងក្រោមល្បះជាលេខសម្រាប់ប្រាប់រនោច) ។

ឧទាហរណ៍ខាងលើនេះ ត្រូវអានថា៖ ភ្នំពេញ, នៅថ្ងៃអាទិត្យ ដប់រោច ខែចេត្រ ឆ្នាំមមែសប្ដស័ក ពុទ្ធសករាជ ពីរពាន់ បួនរយ កៅសិប ប្រាំបី ។

ក) សំនួរ

ចំណុចល្បះ មានទ្រង់ទ្រាយដូចម្ដេច? សម្រាប់ប្រើយ៉ាងណា ខ្ទះកងការសេរសេរ? សម្រាប់ប្រើដូចម្ដេចខាងបន្ទុកគតិ? ចូរលើកឧទាហរណ៍ទាំងអស់មកពន្យល់?

៦) ចម្លើយ

| |
|---|
| |

*  *
*

៕ ៕ ៕ ៕ ៕ ៕ ៕ ៕ ៕ ៕ ៕ ៕ ៕ ៕ ៕ ៕ ៕ ៕

៚ ៚ ៚ ៚ ៚ ៚ ៚ ៚ ៚ ៚ ៚ ៚ ៚ ៚ ៚ ៚ ៚

## (៣) ល្បះចប់[1] (៕)

ខណ្ឌសញ្ញាមួយបែបមានរូបយ៉ាងនេះ (៕) ឬ យ៉ាងនេះ (។៚—) ឬ ក៏យ៉ាងនេះ (៕៚—) សម្រាប់ប្រើខណ្ឌបញ្ចប់សេចក្ដីដែលហើយត្រឹមតែប៉ុណ្ណោះ ឥតមានតទៅទៀត,

ឧទាហរណ៍:

(១) ហៅថា «ល្បះបរិយោសាន» ក៏បាន ។

១ ពាក្យចាស់ពាក្យពីព្រេង ទោសខុសឯង មើលពុំយល់ ........................ អស់អាថ៌ ឱភាទាន ស្រេចប្រការម៉្លេះឯងយោង(១) ។ល។

យ៉ាងនេះ ហៅថា "ល្បះបប់ ឬ ល្បះបរិយោសាន" ។

ល្បះបប់ ឬ ល្បះបរិយោសាន ទាំង ៣ បែបនេះ លោកមិនបានកំណត់ឲ្យប្រើជាដាច់ខាតទេ ប្រើក៏បាន មិនប្រើក៏បាន; សម័យឥឡូវប្រើទន់ប្រើ ខ្ញុំណ្ហា ឬ ល្បះ (។) នេះ ជំនួស ល្បះបប់ ឬ ល្បះបរិយោសាន វិញ);

ក) សំណួរ

ល្បះបប់ ឬ ល្បះបរិយោសាន មានទ្រង់ទ្រាយ ដូចម្ដេច? សម្រាប់ប្រើខណ្ឌអ្វី? ចូរលើកឧទាហរណ៍ មកពន្យល់? ល្បះបរិយោសាន លោកកំណត់ឲ្យប្រើជាដាច់ខាត ឬ មិនប្រើក៏បានដែរ?

(១) សាស្ត្រាពាក្យចាស់ ។

៧] ចម្លើយ

| |
|---|
| . . . . . . . . . . . . |

* *

*

## [៤] គោមូត្រ[១] (៚—)

ខណ្ឌសញ្ញាមួយបែប មានរូបសណ្ឋានស្រដៀងនឹងកក្រាញ់ទឹកនោមគោយ៉ាងនេះ (៚—) សម្រាប់ប្រើសរសេរដាក់ត្រង់កន្លែងបញ្ចប់សេចក្តី ដែលចប់អស់ហើយត្រឹមតែប៉ុណ្ណោះ ;

ឧទាហរណ៍៖

១ ហែមហាជនសប្បុរស ទោះស្រីប្រុស

(១) គោមូត្រ ន. (សំ. ម. គោមុត្ត "ទឹកនោមគោ") ។

កបកិរិយា គួរគិតយកប្រាជ្ញ បង់ហំប្បាប់ជា គន្លង ៗល ៗ ឲ្យបានសុខទាំងបី សុខលោកិយសុខសួគ៌ា សុខដល់និព្វានណា ប្រាប់ធម៌ជាសុខស្របហោង[1] ៚—— យ៉ាងនេះ ហៅថា "គោមូត្រ" ។

(គោមូត្រ (៚—) នេះ អ្នកលក្ខទីបប្រើដាក់ត្រង់ទីបបំផុតនៃគាថាបាលីមួយៗ សំគាល់ជាខ្យល់សំឡេងរនរន្ទាន់ ដូចគង្គាញរលកទឹក តាមទំនងបទ សរភញ្ញ ម្យ៉ាងដែលហៅថា គីវង្គ; ខ្មែរយើងជាន់ដើមប្រើបែបនេះតាមអ្នកលក្ខទីប សម្រាប់ដាក់បំពោះតែត្រង់កន្លែងបញ្ចប់ពាក្យកាព្យឃ្លោង, លុះយូរៗមក ទោះបីពាក្យពយក៏ប្រើ គោ-មូត្រ (៚—) នេះដែរ; សម័យឥឡូវមិនសូវប្រើទេ) ។

ក) សំនួរ

គោមូត្រ មានសណ្ឋានស្រដៀងនឹងអ្វី? សម្រាប់

(១) ច្បាប់ហែមហាជន ។

ប្រើដាក់ត្រង់កន្លែងណាខ្លះ? សម័យឥឡូវគេនៅនិយម ប្រើច្រើនដែរឬទេ?

១] ចម្លើយ

* *
*

## [៩] វ៉ាត់ ឬ ឃ្នាប ({)

ខណ្ឌសញ្ញាមួយបែបមានរូបយ៉ាងនេះ ({) សម្រាប់ ប្រើសរសេរគាបពាក្យទន្ទឹមគ្នា ឬ ប្រមូលគាបសេចក្ដីច្រើន, បទឲ្យទៅជាបទមួយជាមួយគ្នា,

ឧទាហរណ៍:

ថ្ងៃ ៨ (កើត / រោច) នឹង ថ្ងៃ ១៥ (កើត / រោច) ឬ ថ្ងៃ ១៤ រោច ។

ពុន
វែក
សែង
លី
ទូល
ឧទាហរណ៍ទី២: កណ្ដៀត } ត្រូវនឹងពាក្យបារាំងថា (porter) ។
បី
ព
ទ្រ
កាន់
យួរ

ប៉ុន្តែសម័យឥឡូវ ច្រើនប្រើ ក្បៀស (,) ឬ បំណុបក្បៀស (;) នេះ ជំនួសវិញ,

ឧទាហរណ៍ៈ

ថ្ងៃ ៨ កើត, ៨ រោច និង ថ្ងៃ ១៥ កើត, ១៥ រោច ឬ ថ្ងៃ ១៤ រោច ជាថ្ងៃឧបោសថសីល ។

ក) សំនួរ

វ៉ាត់ ឬ ឃ្នាប មានទ្រង់ទ្រាយដូចម្តេច? សម្រាប់ប្រើយ៉ាងណា ខ្លះក្នុងការសរសេរ? បើគេមិនប្រើ ឃ្នាប គេយកអ្វីមកប្រើជំនួស? ចូរលើកឧទាហរណ៍មកមើល?

ខ) ចម្លើយ

* *

*

(៦) វដ្តសញ្ញា (—)

វដ្តសញ្ញា មានរូបសណ្ឋានជាគំនូសខ្វែងយ៉ាងនេះ (—)

សម្រាប់ប្រើគួសក្តិការសេរសេរបានច្រើនយ៉ាង, ដូចមាន ពោលតទៅនេះ ៖

ក) សម្រាប់ប្រើប្រៀតសេចក្តីក្នុងប្រយោគ, សេចក្តីនោះមានសារៈសំខាន់ខ្វះដែរ,

ឧទាហរណ៍: (សម្រាប់ប្រើក្នុងភាសាខ្មែរ)

បុរសម្នាក់បានឃើញពោរម្នាក់ មានពុកមាត់ស្រមូម, រំមុខទុកតែភ្នែក, កាន់កាំភ្លើងនៅដៃ ចូលមក — ក៏ភិតភ័យញ័រអស់ទាំងប្រាណ — រត់ចូលទៅពួនសម្ងំក្នុងផ្ទះ ។

ឬ: បុរសពីរនាក់ — ឪពុកនឹងកូន — នាំគ្នាទៅ កាន …។

ឬថា: រាងកាយរបស់មនុស្សមាន: ក្បាល — ដងខ្លួន — ដៃ — ជើង — សក់ — មុខ — ភ្នែក —

ប្រមុះ — បង្កា — ប្ដាល់ — ប្វាស — ត្របៀក ៗ (ទើននេ

ប្រើគ្រៀសក៏បាន) ។

ឧទាហរណ៍ទី ២: (សម្រាប់ប្រើក្នុងភាសាបាលី)

ធិនា — ហត្ថា — យស្ស — សោ > ធិន្នហត្ថោ

(បុរិសោ) "(បុរស) មានដៃដាច់ហើយ" ។

១] សម្រាប់ប្រើគូសពីមុខលេខរៀង ពាក់ខសេចក្ដី

ក្នុងសៀវភៅ, លក្ខន្តិក:, ប្រការ, មាត្រាឬអត្ថបទណាមួយ,

ឧទាហរណ៍:

១ — អំពីការគំនាប់ទង់ជាតិ . . . . . . . . ;

២ — អំពីការគោរពទង់ជាតិ . . . . . . . ,

៣ — អំពី . . . . . . . . . . . . . . ,

ឬប្រើចុចគូសពីមុខលេខយ៉ាងនេះ (.—) ក៏បាន,

ឧទាហរណ៍:

ប្រការ ១.— ស្ដីអំពី . . . . . . . . . . ;

ប្រការ ២.— . . . . . . . . . . . . . . ;

ឬថា:

មាត្រា ១.- . . . . . . . . . . . . . . ;

មាត្រា ២.- . . . . . . . . . . . . . . ;

គ) សម្រាប់ប្រើក្នុងពាក្យនិយាយឆ្លើយឆ្លងគ្នាទៅវិញទៅមក,

ឧទាហរណ៍:

— នាង! ឯងបានចូលរៀនហើយឬនៅ?

— នៅ ។

— ចុះប្អូននាង?

— ប្អូនខ្ញុំក៏ពុំទាន់បានចូលរៀនដែរ ។

ឃ) សម្រាប់ប្រើដាក់ខាងដើម ឬ ខាងចុងពាក្យានុគណាមួយ ដែលត្រូវការបំពេញ តាមលំនាំសព្ទបន្ទាប់ខាងដើម ឬ ខាងចុង,

ឧទាហរណ៍:

យុទ្ធវិធី, — សាស្ត្រ (អានថា: យុទ្ធវិធី, យុទ្ធ-សាស្ត្រ);

សេចក្ដីសុខ, — ចំរើន (អានថា: សេចក្ដីសុខ, សេចក្ដីចំរើន);

បញ្ញាសម័យ, សាយណ្ហ — (អានថា: បញ្ញាសម័យ, សាយណ្ហសម័យ) ។

ង) សម្រាប់ប្រើដាក់ចុងបន្ទាត់ សំគាល់ស័ព្ទដែលសរសេរឬបោះពុម្ពដល់ចុងបន្ទាត់ហើយ ប៉ុន្តែមិនទាន់អស់ព្យាង្គនៅឡើយ ត្រូវអានភ្ជាប់ទៅនឹងព្យាង្គខាងដើមបន្ទាត់ជាលំដាប់,

ឧទាហរណ៍:

នគរវត្តជាប្រាសាទមួយល្អជាងគេក្នុងចំ–ណោមនៃប្រាសាទទាំងឡាយនៅអង្គរ ...។

ប៉ុន្តែមិនត្រូវប្រើ វជ្ជសញ្ញា បែបនេះ ឲ្យខូចព្យាង្គនៃ

ស័ព្ទ, ដូចជា ... ហើ—យ, សរសេ—រ ។ល។

យ៉ាងនេះទៀយ, ត្រូវប្រើតែនៅទីបំផុតពាក្យនៃស័ព្ទដែលជាពហុពាក្យ ។

៣) សម្រាប់ប្រើគួសក្នុងការកត់ត្រាគោត្តនាម និងបកតិនាម,

ឧទាហរណ៍:

គួង-ប្រិយា, គួង-សោភ័ណ, គួង-សុគន្ធី, គួង-សុគន្ធារី ។

មានសញ្ញា ២ យ៉ាងទៀត ដែលលោកពប់បញ្ចូលក្នុងពួករជ្ជុសញ្ញា (–) នេះដែរ ព្រោះមានទ្រង់ទ្រាយដូចគ្នា ប្លែកគ្នាតែវិធីប្រើបន្តិចបន្តួច, ដូចមានពោលតទៅនេះ ៖

១) យតិភង្គ[១] ជាសញ្ញាមួយបែប មានរូបដូចរជ្ជុសញ្ញា (–) នេះដែរ សម្រាប់ប្រើដាក់ត្រង់ចន្លោះ

(១) ហៅថា "សហសញ្ញា" ក៏បាន ប៉ុន្តែមិនសូវប្រើ ។

សង្កាត់ពាក្យមួយម៉ាត់ដែលផ្ដាច់ចេញដោយខ្លួនពីគ្នា ត្រង់ចនោះឃ្លាគាថា, កាព្យ, ឃ្លោង,

ឧទាហរណ៍: (ខាងភាសាបាលី)

ទុហេតុកាមតា សត្ត- បត្តាវ្ហស តិហេតុកា ។

ឧទាហរណ៍: (ខាងភាសាខ្មែរ)

ប្ញាប់នេះបើប្ញា គួរឲ្យអស់មហា- ជនផង

ត្រង់ត្រាប់ . . . ។

សត្ត និង បត្តាវ្ហស ត្រូវភ្ជាប់គ្នា មហា និង ជន ក៏ត្រូវភ្ជាប់គ្នាដែរ, បែរជាផ្ដាច់ពីគ្នាតាមឃ្លារបស់កាព្យ, ត្រូវប្រើគ្រឿងសញ្ញា (–) នេះ ជាសំគាល់ឲ្យដឹងថាជាពាក្យភ្ជាប់គ្នា, យ៉ាងនេះ ហៅថា "យតិភង្គ" ។

ឧទាហរណ៍ទី ២:

ស្រគត់អស់តិ- ត្រៃយអង្គអចិ- ត្រៃយទ្រង់

ករុណា សព្វសត្វដាក់ដល់ មណ្ឌលសួគ៌ា គុណ

គាប់ជាតិជា ស្រូវស្រែផលបុណ្យ . . .;

ឧទាៈ ជ្បិតសីលជាយាន នាំរូបរូបបាន បៀស បាកបតុរា- បាយបាបបានដល់ មណ្ឌលសួគ៌ា- ល័យលុះមហា- និព្វានសេដ្ឋ(១). . ។

២) នយសញ្ញា ជាសញ្ញាមួយបែប មានរូបដូចវជ្ជិសញ្ញា (–) នេះដែរ, សម្រាប់ប្រើគូសក្រោមពាក្យដែលមានសេចក្ដីដូចគ្នាពីលើមក ឬ សម្រាប់ប្រើគូសពីក្រោមពាក្យដែលត្រូវទន្ទេញឲ្យចាំមាត់ ឬ ប្រើគូសក្រោមពាក្យសំខាន់ណាមួយ ដើម្បីធ្វើពាក្យនុះឲ្យឃើញជាក់ស្ដែងឡើង,

ក) ប្រើគូសក្រោមពាក្យដែលមានសេចក្ដីដូចគ្នាពីលើមក,

ឧទាហរណ៍:

ថ្ងៃអាទិត្យ ៩ រោច ខែពិសាខ

(១) ច្បាប់សុភាសិត ។

ថ្ងៃ ច័ន្ទ ១០ កោប ខែពិសាខ

— អង្គារ ១១ — —

— ពុធ ១២ — —

— ព្រហស្បតិ៍ ១៣ — —

— សុក្រ ១៤ — —

— សៅរ៍ ១៥ — —

បើនឹងប្រើក្បៀសពីរ ( ,, ) ដូច្នេះក៏បាន ឬប្រើតួអក្សរ (–ដ–) នេះ ដោយសំគាល់សេចក្ដីថា "ដូចគ្នា" ដូច្នេះក៏បាន តាមចូលចិត្តប្រើ ។

១) សម្រាប់ប្រើគូសពីក្រោមពាក្យដែលត្រូវទន្ទេញឲ្យចាំមាត់,

ឧទាហរណ៍:

គុណនាមមាន ៣ យ៉ាងគឺ ៖ <u>បកតិគុណនាម ១</u>, <u>វិសេសគុណនាម ១</u> នឹង <u>អតិវិសេសគុណនាម ១</u> ។

គ) សម្រាប់ប្រើគួសពីក្រោមពាក្យសំខាន់ ដើម្បីធ្វើពាក្យនោះឲ្យឃើញជាក់ស្តែងឡើង,

ឧទាហរណ៍:

ព្រាហ្មណ៍គិតថា: "កូនទាំងឡាយរបស់អញមាន៤នាក់, អញនឹងឲ្យទ្រព្យដំនុំកូនទាំងឡាយ ៤ នាក់នោះ ដល់កូនម្នាក់" ។

(យតិភង្គ និង ឆយសញ្ញា ទាំង២យ៉ាងដូចពោលមកហើយនេះ មានរូបជាគំនូសខ្វែ (–) ដូចគ្នានឹង វជ្ជិសញ្ញា ដែរ ប៉ុន្តែគ្រាន់តែវិធីប្រើបន្តិចបន្តួច, ដូច្នេះគួរយើងកំណត់ហៅថា "វជ្ជិសញ្ញា" ដូចគ្នាទាំងអស់កបាន ដើម្បីឲ្យងាយដល់ការអាន និង ការចំណាំ) ។

ឃ) សំនួរ

វជ្ជិសញ្ញា មានសណ្ឋានដូចជាអ្វី? សម្រាប់ប្រើបានយ៉ាងណា ខ្លះក្នុងការសរសេរ? ចូរលើកឧទាហរណ៍គ្រប់

ៗមកពន្យល់? មានសញ្ញាអ្វីទៀត ដែលប្រើដូចគ្នានឹងវជ្ឈសញ្ញា នេះ? ចូររាប់ឈ្មោះមកមើល? ក្នុងសញ្ញានីមួយៗ មានវិធីប្រើដូចម្ដេចខ្លះ? ចូរនាំយកសញ្ញាមួយម្ដងៗមកអធិប្បាយជាឧទាហរណ៍ គ្រប់ៗ ទាំងអស់ឲ្យល្មមស្ដាប់បាន? សញ្ញាទាំង ២ យ៉ាងខាងក្រោយ បើយើងហៅថា “វជ្ឈសញ្ញា” តែម្យ៉ាងបានដែរឬទេ?

១) ចម្លើយ

... ... ... ... ... ... ... ... ... ... ...

## (៧) មជ្ឈណ្ឌសញ្ញា[១] (...)

ខណ្ឌសញ្ញាមួយបែប មានរូបយ៉ាងនេះ (...)

(១) ហៅថា “ពងត្រី” ក៏បាន ។

សម្រាប់ប្រើក្នុងការ “រាប់ហេតុ, របស់, ប្រដាប់ប្រដា” ជាដើម ដែលមានទំនងដូចគ្នា ឬស្រដៀងគ្នា ដែលអ្នកសរសេរ ឬ បោះពុម្ព ពុំបាននាំយកមករៀបរាប់ដោយសព្វគ្រប់ នៅមានច្រើនតទៅទៀត, មានអត្ថន័យប្រហែលគ្នានឹងពាក្យថា “ជាដើម”,

ឧទាហរណ៍:

សាលារៀនខ្ញុំមាន: តុ, ទូ, កៅអី . . . ។

សម្រាប់ប្រើចុច “លិខិត, បណ្ណ, វិក្កយប័ត្រ, វត្តបទ ឬ មេរៀនផ្សេងៗ” ត្រង់ចន្លោះដែលគេទុកចំហឲ្យចុះសេចក្ដីបំពេញតាមមុខការដែលត្រូវបំពេញ,

ឧទាហរណ៍:

សូមទានខ្ញុំប្របាទ ឬ នាងខ្ញុំឈ្មោះ . . . . .
អាយុ . . . ឆ្នាំ, ជាតិ . . . . . របររកស៊ី . . . . .
ទីលំនៅៗឃុំ . . . ស្រុក . . . . . ខេត្ត . . . . ។

ដូចជាៈ រាល់យប់ខ្ញុំទទួលទានដំណេកក្នុង.... ជាមួយនឹងបងខ្ញុំ, ក្នុងមុងខ្ញុំមាន .... សម្រាប់កើយ, មាន ...... សម្រាប់ដណ្ដប់ ។ល។

មួយយ៉ាងទៀត, មច្ឆណ្ឌសញ្ញា (...) នេះ សម្រាប់ប្រើក្នុងពេលដែលមានសេចក្ដីព្រួយកង្វល់ ឬ មានអារម្មណ៍ដទៃណាមួយ ចូលមកច្របូកស្ទះគំនិតកាត់ផ្ដាច់ប្រយោគដែលបានផ្ដើមនិយាយមិនឲ្យពោលតទៅទៀតបាន,

ឧទាហរណ៍ៈ

ខ្ញុំ...; យី!...; យីអើ!...; យីអើហ្ន៎!... ។

(មច្ឆណ្ឌសញ្ញា (...) នេះ លោកកំណត់ឲ្យប្រើ ចុច ៣, បើមានពាក្យវែង ឲ្យប្រើ ចុចបន្ថែមបីៗជាលំដាប់តទៅ, កុំប្រើ ចុច ២, ចុច ៤ ឬ ចុច ៥ ដូច្នេះឡើយ) ។

មួយបែបទៀត, សម្រាប់ប្រើដាក់ខាងដើមប្រយោគ ដើម្បីឲ្យដឹងថាមានសេចក្តីពីខាងដើមមកច្រើន ប៉ុន្តែអ្នកសរសេរចាប់ច្បួយកតែត្រង់កន្លែងខាងចុង ដ៏ជាសេចក្តីសំខាន់ដែលខ្លួនត្រូវការ,

ឧទាហរណ៍:

បោរាណាចារ្យ លោកប្រដៅថា:

"...ធម្មតាអ្នកជាជាតិ កាលគេអាទ៌ឲ្យគិតគូរ...;

៣) សំនួរ

មប្ពុណ្ណសញ្ញា មានសណ្ឋានដូចជាអ្វី? សម្រាប់ប្រើចុះក្នុងការសរសេរ? មានអត្ថន័យដូចម្តេច? ចូរលើកឧទាហរណ៍មកពន្យល់មើល?

៤) ចម្លើយ

* * *

| (។បេ។)ឬ(។ល។) | (។បេ។)ឬ(។ល។) | (។បេ។)ឬ(។ល។) |
|---|---|---|
| (៚លៈ)ក៏(៚ណៈ) | (៚លៈ)ក៏(៚ណៈ) | (៚លៈ)ក៏(៚ណៈ) |

## (៨) បេយ្យាល (។បេ។)ឬ(។ល។)

ខណ្ឌសញ្ញាមួយបែប សម្រាប់ប្រើបំព្រួញសេចក្តីវែងឲ្យខ្លី ឬ ច្រើនឲ្យតិច, ប្រើតែអក្សរ ១ តួខាងដើមថា ។បេ។ (អានថា ប៉េ) ក៏បាន, ប្រើតែអក្សរ ១ តួខាងចុងថា ។ល។ (អានថា ល៉ះ) ក៏បាន;

ក្នុងភាសាខ្មែរច្រើនប្រើ (។ល។) នេះ,

ឧទាហរណ៍:

ប្រដាប់ប្រដាដែលខ្ញុំយកទៅរៀនមានច្រើនមុខ គឺសៀវភៅសរសេរ, សៀវភៅអាន, ដងប៉ាកការ បន្ទាត់, ទឹកខ្មៅ ។ល។

ក្នុងភាសាបាលីច្រើនប្រើ (។បេ។) នេះ,

ឧទាហរណ៍:

នមោ តស្ស ភគវតោ ។ល។

ឬ នមោ ។ល។ សម្មាសម្ពុទ្ធស្ស ។

ក) សំនួរ

បេយ្យាល មានសណ្ឋានដូចអ្វី? សម្រាប់ប្រើដូចម្ដេចក្នុងការសរសេរ? ចូរលើកឧទាហរណ៍មកមើល?

ខ) ចម្លើយ

* * *

(·) (·) (·) (·) (·) (·) (·) (·) (·) (·) (·) (·) (·)
(·) (·) (·) (·) (·) (·) (·) (·) (·) (·) (·) (·)

## (៩) អាទិសង្កេត[១] (·)

ខណ្ឌសញ្ញាមួយបែបមានរូបសណ្ឋានជាចំណុចមួយ

---

(១) ហៅថា "អក្សរសង្ខេប" ក៏បាន; មើលក្នុងវចនានុក្រម "ពួកអក្សរកា" ។

យ៉ាងនេះ (·) សម្រាប់ប្រើចុចពាក្យវែងបំព្រួញឲ្យទៅជាអក្សរសង្ខេប គឺយកតែអក្សរមួយគួៗ ខាងដើម ពីក្នុងពាក្យមួយ ៗ មកប្រើ ដើម្បីកុំឲ្យពិបាកសរសេរវែងពេក ព្រោះជាពាក្យដែលគេត្រូវប្រើញឹកញាប់, គេអាចដឹងគ្រប់គ្នា,

ឧទាហរណ៍:

កិ. (គឺកិរិយាស័ព្ទ); គុ. (គឺគុណស័ព្ទ); ន. (គឺនាមស័ព្ទ); និ. (គឺនិបាតស័ព្ទ); ឧ. (គឺឧទានស័ព្ទ); ឧទា. (គឺឧទាហរណ៍); ព. ស. (គឺពុទ្ធសករាជ); គ. ស. (គឺគ្រិស្តសករាជ); ភ. ព. (គឺភ្នំពេញ) ជាដើម ។

សម្រាប់ប្រើចុចក្នុងការសរសេរលេខ ត្រង់ខ្ទង់ពាន់ ដើម្បីឲ្យស្រួលអាន,

ឧទាហរណ៍:

៣៥.១៦២ ។ ៨៧.២៦៣ ។ ២.៤៩៨ ។

ប៉ុន្តែក្នុងការពប់សករាជ មិនត្រូវប្រើចំណុចនេះទេ ។

ក) សំនួរ

អាទិសង្កេត មានសណ្ឋានដូចម្តេច? សម្រាប់ប្រើចុចយ៉ាងណាខ្លះក្នុងការសរសេរ? ចូរលើកឧទាហរណ៍មកពន្យល់?

១) ចម្លើយ

| |
|---|
| |

* * *

(') (') (') (') (') (') (') (') (') (') (')
(,) (,) (,) (,) (,) (,) (,) (,) (,) (,) (,)

[១០] ក្បៀស(១) ( , )

ខណ្ឌសញ្ញាមួយបែប មានរូបយ៉ាងនេះ ( , ) សម្រាប់

(១) ច្បាប់ខ្លះហៅថា ''ចុល្លភាគ'' ។

ប្រើញែកសេចក្តីកន្ត្រៃយោគជាភាគតូចៗ, ប៉ុន្តែតាមធម្មតា គេច្រើនតែប្រើដកឃ្លា,

មានពាក្យពិសេសខ្លះដែលគួរប្រើក្បៀស (,) នេះ,

ឧទាហរណ៍:

ទង់ជាតិមាន ៣ ពណ៌គឺៈ ខៀវ, ស, ក្រហម ។

សម្រាប់ប្រើកន្លែងការរាប់ឈ្មោះ ឬរាប់វត្ថុមួយៗ,

ឧទាហរណ៍:

ឈ្មោះ ក ១, ឈ្មោះ ខ ១, ឈ្មោះ គ ១, ឈ្មោះ ឃ ១ ទាំង ៤ នាក់នេះត្រូវជាបងប្អូនបង្កើតនឹងគ្នា ។

ឧទាហរណ៍ ទី ២:

រាប់ចំនួនរបស់, ដូចជា: តុ, ទូ, កៅអី... ។

ក្រៅពីនេះនៅមានច្រើនទៀតកន្លែងការរាប់ចំនួន,

ឧទាហរណ៍:

៣ម៉,៣៦ ។ ៦៣ស៊,២១ ។ល។

ក) សំនួរ

ក្បៀស មានសណ្ឋានដូចម្តេច? សម្រាប់ប្រើយ៉ាងណាខ្លះក្នុងការសរសេរ? ចូរនាំឧទាហរណ៍មកពន្យល់ផង?

១) ចម្លើយ

* * *

## (១១) បំណុចក្បៀស[១] ( ; )

ខណ្ឌសញ្ញាមួយបែប មានរូបយ៉ាងនេះ ( ; ) សម្រាប់ប្រើញែកសេចក្តីជាភាគ តែភាគនោះធំជាងភាគដែលញែក

(១) ច្បាប់ខ្លះហៅថា "មហាភាគ" ។

ដោយដកឃ្លា ឬ ដោយក្បៀស ប៉ុន្តែតូចជាងភាគដែល

ញែកដោយខណ្ឌ ឬ ល្បះ,

ឧទាហរណ៍:

រូបទង់ជាតិទាំងមូល ជាតំណាងកេរ្តិ៍មរតក

ជាតិ ដែលពេញបរិបូណ៌ដោយជ័យជំនះ; ជា

តំណាងនៃសេចក្ដីបិប្ដើងរុងរឿង, សេចក្ដីថ្លៃថ្នូរនឹង

ការស៊ូស្លាប់រស់, ជាតំណាងសេរីភាពរបស់ជាតិ

និងដួងកែវរបស់ប្រទេស; . . . . . . . ។

(:) ការសំនួរ

ចំណុចក្បៀស មានទ្រង់ទ្រាយដូចម្ដេច? សម្រាប់

ប្រើយ៉ាងណាខ្លះក្នុងការសរសេរ? ចូរលើកឧទាហរណ៍

មកពន្យល់ផង?

ខ) ចម្លើយ

| |
|---|
| |

* *
*

## (១២) បំណុចពីរគូស(១) (៖)

ខណ្ឌសញ្ញាមួយបែបមានរូបយ៉ាងនេះ ( ៖ ) សម្រាប់ប្រើដាក់ពីមុខសេចក្ដីដែលបំរុងនឹងរៀបរាប់ ឬ បំរុងនឹងអធិប្បាយតទៅ,

ឧទាហរណ៍:

ព័ណ៌និងរូបភាពទង់ជាតិរបស់ប្រទេសកម្ពុជា មានការសំគាល់ដូចតទៅនេះ ៖

---

(១) ហៅថា "ទ្វិពិន្ទុលេខ" ក៏បាន ។

ក) ពណ៌នៃជាតិ

១.- ខៀវ ជាសញ្ញានៃសេចក្ដីសុភាព, ទន់ភ្លន់, ស្លូតត្រង់ ។

២.- ស ជាសញ្ញានៃសេចក្ដីសុចរិត, យុត្តិធម៌, បរិសុទ្ធ ។

៣.- ក្រហម ជាសញ្ញានៃសេចក្ដីអង់អាច ក្លាហាន ។

ចូរសំគាល់: បំណុបពីរគូស (ឱ) នេះ ហៅថា "ទ្វិពិន្ទុលោ" ក៏បាន ព្រោះមាន ពិន្ទុ ពីរ មាន គំនូស មួយនៅចន្លោះកណ្ដាលជាគ្រឿងសំគាល់ ដើម្បីកុំឲ្យច្រឡំនឹង វិសជ្ជនីយ (ះ) នេះ ។

បើនឹងប្រើ យុគលពិន្ទុ (:) នេះ តាមទម្លាប់ដើម មកក៏បានដូចគ្នា ។

គ) សំនួរ

បំណុបពីរគូស មានសណ្ឋានដូចម្ដេច? មានអ្វី

ជាគ្រឿងសំគាល់គួរឲ្យចំណាំបាន? មានទ្រង់ទ្រាយបែកគ្នានឹង យុគលពិន្ទុ វិសជ្ជនីយ យ៉ាងណាខ្លះ? ចូរលើកឧទាហរណ៍មកពន្យល់?

១) ចម្លើយ

* * *

? ? ? ? ? ? ? ? ? ? ? ? ? ?

(១៣) បុប្ផសញ្ញា (?)

ខណ្ឌសញ្ញាមួយបែប មានរូបយ៉ាងនេះ (?) សម្រាប់ប្រើដាក់ខាងចុងនៃប្រយោគសួរ, ផណ្ដឹង, ឆ្ងល់ឬសង្ស័យ,

ឧទាហរណ៍ៈ

អ្នកឈ្មោះអី ?

– នៅស្រុកណា ?

– មកមានការអី ?

– ម៉េបទៅ ! រឿងអ្នក ?

– ឱ ! ដូច្នោះឬ ?

ក) សំនួរ

បុច្ឆសញ្ញា មានរូបដូចម្ដេច? សម្រាប់ប្រើដាក់អ្វី?

ចូរលើកឧទាហរណ៍មកមើល?

១) ចម្លើយ

| |
|---|
| |

*
* *

¡!¡!¡!¡!¡!¡!¡!¡!¡!¡!¡!¡!¡!¡

## [១៤] ឧទានសញ្ញា (!)

ឧទានសញ្ញាមួយបែប មានរូបយ៉ាងនេះ (!) សម្រាប់ប្រើក្នុងការបន្លឺ ឬ កំទរសំដីញ៉ាំងៗ ដោយមានអំណរ, ទុក្ខព្រួយ, ការសើច, ហេតុអស្ចារ្យ, សេចក្ដីសប់ស្ញែង, ការភ្ញាក់, ភ័យ, សេចក្ដីឆ្ងល់, ក្រោធ, ការស្ងួន, ការតក់ស្លុត, សំរេក, តំអូញ, សេចក្ដីឈឺចាប់ខ្លាំង, ការអស់ចិត្ត ឬ ការយល់សេចក្ដីជាក់ ។ល។,

ឧទាហរណ៍:

អ៊ីតប៉ុនអញ!; អើ! មែនហើយ!; ឱ! ពុទ្ធោ អើយពុទ្ធោ!; ឱ! រូបអើយរូបលំបាកអ្វីម៉្លេះទេ!; ឱ! ដូច្នោះទេតើ!; ណ្ហើយ! ឯវិត្រឹមណាំងបុះ!; ក្បាច់បម្លាក់ធ្លាក់លើជញ្ជាំងឬប្រាសាទនគរវត្តនៅរស់

រងើក! គួរឲ្យអស្ចារ្យមែនហ្ន៎ះ!; យី៎ះ! ម៉េចអីបេះ!; យី៎ះ! ពស់ធំណាស់!; អើ! ម៉េចទៅកូនអ្នករៀនដល់ណាហើយ?; ទៅៗ!; ឱ! កូនអើយកូន! មិនគួរនឹងព្រាត់ពោលម្ដាយសោះ!; អែយ៉ះ!; អែយ៉ូយ!; អ៊ូយ!; អ៊ែយ៉ា!;...។

ឧទានសព្ទនេះ បើចែកជាឈ្មោះមាន ៣ យ៉ាងគឺ:

១) សព្ទណាដែលប្រើបន្ទឺ ឬ កំទរស់ដីចំពោះពាក្យ ដូចជា: "ស្ញើប, អស្ចារ្យ ឬ ពាក្យស្ញប់ស្ញែង" ជាដើម ហៅថា "អច្ឆរិយសព្ទ" ។

២) សព្ទណាដែលប្រើបន្ទឺ ឬ កំទរស់ដីចំពោះពាក្យ ដូចជា: "សរសើរ, ស្រឡាញ់ ឬ គាប់ចិត្តនឹងរបស់អ្វីមួយ" ជាដើម ហៅថា "វិម្ហយសព្ទ" ។

៣) សព្ទណាដែលប្រើបន្ទឺ ឬ កំទរស់ដីចំពោះ

ពាក្យ ដូចជាៈ "មានទុក្ខព្រួយ" "មានសេចក្ដីសំវេគ" ជាដើម ហៅថា "សំវេគសញ្ញា" ។

សេចក្ដីសំគាល់ៈ

(អច្ឆរិយសញ្ញា, វិម្ហយសញ្ញា, សំវេគសញ្ញា ទាំង៣ យ៉ាងនេះ បើនឹងហៅថា "ឧទានសញ្ញា" តែម្យ៉ាងក៏បាន ព្រោះមានគំនូសយ៉ាងនេះ (!) ជាគ្រឿងសំគាល់ដូចៗគ្នាទាំងអស់) ។

គ) សំនួរ

ឧទានសញ្ញា មានទ្រង់ទ្រាយដូចអ្វី? សម្រាប់ប្រើជាក់មុខពាក្យយ៉ាងណាខ្លះ? ចូរលើកឧទាហរណ៍មកពន្យល់? បើចែកជាឈ្មោះមានប៉ុន្មានយ៉ាង? ហៅអ្វីខ្លះ? ចូរពប់ឈ្មោះហើយទាញយកឧទាហរណ៍មកពន្យល់ផង? បើនឹងហៅថា "ឧទានសញ្ញា" តែម្យ៉ាងបានឬទេ?

១) ចម្លើយ

* * *

| | | | |
|---|---|---|---|
| (“ ”) ឬ (« ») | (“ ”) ឬ (« ») | (“ ”) ឬ (« ») | (“ ”) ឬ (« ») |
| („ ”) ឬ (« ») | („ ”) ឬ (« ») | („ ”) ឬ (« ») | („ ”) ឬ (« ») |

## (១៩) វិទ្ធារសញ្ញា[១] („ ”) ឬ (« »)

ខណ្ឌសញ្ញានេះ មានសណ្ឋានជា ២ បែបយ៉ាងនេះ („ ”) ឬក៏យ៉ាងនេះ (« »)[២] សម្រាប់ប្រើពាំងពាក្យ ឬ ពាំងសេចក្ដីរបស់អ្នកដទៃ ដែលគេនាំយកមកសរសេរក្នុងប្រយោគមួយ ៗ

---

(១) ហៅថា „អញ្ញប្រកាស” ក៏បាន ។

(២) នឹងហៅថា „កោណសញ្ញា” ដើម្បីស្រួលចំណាំកុំឲ្យច្រឡំគ្នាក៏បាន ។

ឧទាហរណ៍ទី ១ :

កាលព្រះសក្យមុនីសម្មាសម្ពុទ្ធ ទ្រង់ជិតបរិនិព្វាន ទ្រង់ផ្តាំថា: "ម្នាលអានន្ទ! អំណើះតពីតថាគតទៅ ធម៌វិន័យនឹងជាសាស្តានៃអ្នកទាំងឡាយជាតំណាងតថាគត" ។

ឧទាហរណ៍ទី ២ :

បរាជ័យ "ចាញ់" អបរាជ័យ "ឈ្នះ, ជំនះ" ។

ឧទាហរណ៍ទី ៣ :

*រូបប្រាសាទដែលតាំងនៅចំកណ្តាលផ្ទៃទង់ជាតិខ្មែរនោះ លោកសំដៅយកប្រាសាទនគរវត្តជាក់ស្តាំងថា ៖*

«ក្នុងពិភពលោក ពុំមានប្រទេសណាមួយ មានប្រាសាទបុរាណធំសម្បើមដូច្នេះឡើយ» ។ *ប្រាសាទនេះជាទីប្រតិស្ឋានសាសនាផង ។*

វិទ្យាសញ្ញានៃកោណសញ្ញា ( " " ឬ « » ) *នេះ ក្នុងភាសាបាលីក៏មានយកមកប្រើជាលេខក្នុងខ្លះដែរ )* ។

ក) សំនួរ

វិទ្យាសញ្ញា មានទ្រង់ទ្រាយដូចអ្វី? មានប៉ុន្មានបែប? ហៅបានយ៉ាងណាខ្លះ? សម្រាប់ប្រើដូចម្ដេចខ្លះក្នុងការសរសេរ? ចូរទាញឧទាហរណ៍មកពន្យល់?

ខ) ចម្លើយ

* * *

(‘ ’) (‘ ’) (‘ ’) (‘ ’) (‘ ’) (‘ ’) ‘ ’) ‘ ’)

(‘ ’) (‘ ’) (‘ ’) (‘ ’) (‘ ’) (‘ ’) (‘ ’) (‘ ’

[១៦] អន្តរសញ្ញា[១] (‘ ’)

ខណ្ឌសញ្ញាបើកបិទមានរូបសណ្ឋានយ៉ាងនេះ (‘ ’)

(១) ព្រះគ្រូសង្ឃសត្ថា (ប៉. ស. ធម្មាភោ) រៀបរៀងបន្ថែម ។

សម្រាប់ប្រើបើកបិទពាំងសេចក្ដីដែលអ្នកដទៃនិយាយ ហើយអ្នកម្នាក់យកសេចក្ដីនោះមកនិយាយដំណាល ឬប្រាប់គំនិតរបស់ខ្លួន នោះត្រូវយកខណ្ឌសញ្ញានេះដាក់ពាំងដើម្បីកុំឲ្យច្រឡំសេចក្ដីដែលបាននិយាយរួចហើយ នឹងសេចក្ដីដែលត្រូវនិយាយតទៅទៀត,

ឧទាហរណ៍:

... កុមារនោះមកដល់ក៏និយាយប្រាប់សំឡាញ់ថា: "ខ្ញុំពុំបានមកជួបភ្លាម ព្រោះក្នុងពេលដែលខ្ញុំបានទៅដល់ផ្ទះ ស្រាប់តែម្ដាយខ្ញុំប្រាប់ថា: 'ព្រឹកនេះ ឯងត្រូវនៅចាំផ្ទះ ព្រោះអញមិននៅ', ទើបខ្ញុំពុំអាចចៀតមកបាន..." ។

ឧទាហរណ៍ទី ២:

"ខ្ញុំគិតថា: 'ថ្ងៃនេះ គ្មាននរណាមកទេ' បានជាខ្ញុំគ្មានប្រុងប្រៀបអ្វីសោះ..." ។

អ្នករៀនភាសាបាលី តែងហៅដោយទម្លាប់ថា "សញ្ញាលេខក្នុងជាន់ទី ២",

ឧទាហរណ៍:

"នាហំ ឯវំ វទាមិ, ឯកស្មឹ បន បិណ្ឌចារិកត្ថេរេ ឃរទ្វារេ ឋិតេ, សស្សុពេ មេ អបេយ្យាទកំ មធុបាយាសំ បរិភុញ្ជន្តោ តំ ន មនសិករោតិ, អហំ 'មយ្ហំ សស្សុយា តមស្មឹ អត្តភាវេ បុញ្ញំ ន ករោតិ បុរាណបុញ្ញ-មេវ ខាទតីតិ ចិន្តេត្វា 'អត្ថិបិ ភន្តេ, មយ្ហំ សស្សុយា បុរាណំ ខាទតីតិ អវចំ; ឯត្ថ មេ កោ ទោសោ ។

ក] សំណួរ

អត្ថសញ្ញា មានរូបសណ្ឋានដូចអ្វី? សម្រាប់ប្រើបិទរាំងសេចក្តីយ៉ាងណាខ្លះ? ចូរលើកឧទាហរណ៍មកពន្យល់ឲ្យសព្វគ្រប់មើល?

១) ចម្លើយ

|  |
|---|
|  |

* *
*

[( )] [( )] [( )] [( )] [( )] [( )] [( )] [( )]

[( )] [( )] [( )] [( )] [( )] [( )] [( )]

[១៧] វង់ក្រចក(១) [( )]

ខណ្ឌសញ្ញាមួយគូមានរូបសណ្ឋានដូចជាវង់ក្រចកយ៉ាងនេះ [( )] សម្រាប់ប្រើបិទរាំងសេចក្ដីដែលមានដំណើរដោយឡែក, សេចក្ដីរាយរង, សេចក្ដីបន្ទាប់បន្សំ ឬ ប្រើរាំងពាក្យខែដាដើម,

---

(១) ហៅថា " នខសញ្ញា " ក៏បាន ៕

ឧទាហរណ៍:

សុគមង្គល! ពាក្យប្រើដោយសន្មតិ (តាមសម័យនិយម) សម្រាប់ឲ្យពរដល់អ្នកដែលរៀបចេញដំណើរទៅកាន់ទីឆ្ងាយ: សុគមង្គល! "សូមអញ្ជើញទៅឲ្យសុខសប្បាយ!" (ប្រើជា សុយាត្រា! ដូច្នេះក៏បាន);

ឧទាហរណ៍ទី ២:

អស្សេន (យុត្ដោ) — រថោ > អស្សរថោ "រថ (ដែលជនទឹមហើយ) ដោយសេះ";

សេចក្ដីកន្សែងក្រុបក នេះ បើគេមិនប្រើកបាន ឥតមានធ្វើឲ្យខូចសេចក្ដីកន្សែងប្រយោគទេ ។

ក) សំណួរ

វង្កក្រុបក មានសណ្ឋានដូចម្ដេច? សម្រាប់ប្រើបទកាំងសេចក្ដីយ៉ាងណាខ្លះ? បើគេមិនប្រើបានឬទេ? ចូរលើកឧទាហរណ៍មកមើល?

## ១) ចម្លើយ

* * *

([ ]) ([ ]) ([ ]) ([ ]) ([ ]) ([ ])

([ ]) ([ ]) ([ ]) ([ ]) ([ ]) ([ ])

## (១៨) វង់ដង្កៀប[១] ([ ])

ខណ្ឌសញ្ញាមួយគូមានរូបសណ្ឋានយ៉ាងនេះ ([ ]) សម្រាប់ប្រើដូចគ្នានឹងវង់ក្រចកធម្មតាដែរ, ប៉ុន្តែគេច្រើនប្រើចំពោះសេចក្តីត្រង់ណាដែលគេមានវង់ក្រចកធម្មតារួចមកហើយ ឬ សម្រាប់ប្រើរាំងលេខមាតិកាជាដើម,

(១) សម្តេចព្រះមហាសុមេធាធិបតី (ជ. ណា. ជោតញ្ញាណោ) សង្ឃនាយកគណៈមហានិកាយ ឲ្យឈ្មោះថា « វង់ដង្កៀប » ។

ឧទាហរណ៍ៈ

ប្រាសាទបាយ័ន តាំងនៅបំកណ្ដាលនគរធំ ហៅថា "យសោធរគិរី" ប្រែថា "ភ្នំទ្រង់យស" ព្រះបាទជ័យវរ្ម័នទី៧ (jayavarman VII) ទ្រង់កសាង ក្នុងរវាង ព.ស. ១៧៤៣ ទៅ ១៨០០); ប្រាសាទនេះមានកំពស់ ៤៥ ម៉ែត្រ ... ។

*សម្រាប់ប្រើក្នុងគណិតសាស្ត្រ,*

ឧទាហរណ៍ៈ

[(− ២៤) × (+ ៣២) × (− ១៦)]: (− ៤)

ឬ $[2x + y - (x + 2y)] \times [3x - 2y - (2x - 3y)]$.

*សម្រាប់ប្រើកំនលេខមាតិកាដែលគេនាំយកមកប្រើដាក់រៀននៅខាងដើមសេចក្ដីសំខាន់ៗ,*

ឧទាហរណ៍ៈ

(១២៨) នាមសព្ទតាំងពី ២ បទឡើងទៅដែលបំព្រួញរួមបួលគ្នាជាបទមួយហៅថា "សមាស";

ក) សំណួរ

វង់ដង្កៀប មានសណ្ឋានដូចអ្វី? សម្រាប់ប្រើបិទរាំងសេចក្ដីយ៉ាងណាខ្លះ? យកមកប្រើរាំងឃ្នាលេខបានឬទេ? ប្រើក្នុងគណិតសាស្ដ្របានឬទេ? ចូរលើកឧទាហរណ៍មកពន្យល់?

(វង់ដង្កៀប (( )) នេះ ក្នុងសៀវភៅព្រះត្រៃបិដកសម្រាយ ក៏មានយកមកប្រើរាំងលេខមាតិកាដែរ);

១) ចម្លើយ

* *
*

[ ] [ ] [ ] [ ] [ ] [ ] [ ] [ ] [ ]

[ ] [ ] [ ] [ ] [ ] [ ] [ ] [ ] [ ]

## (១៩) វង់ក្រចកចំហៀង(១) [ ]

ខណ្ឌសញ្ញាមួយបែប មានរូបសណ្ឋានដូចវង់ក្រចកមួយចំហៀងយ៉ាងនេះ [ ] សម្រាប់ប្រើកំងលេខ ឬ កំងអក្សរមួយតួៗ ដែលគេយកមកប្រើរៀងជាមាតិកាពប់អង្គសេចក្ដីក្នុងសៀវភៅ, ក្បួនច្បាប់, លក្ខន្តិកៈ ឬ លិខិតផ្សេងៗ ។ល។

ឧទាហរណ៍:

អំពីមហាសន្និបាត

សមាជិកទាំងឡាយនៃគណៈកម្មាធិការ មករួមប្រជុំគ្នាជាមហាសន្និបាតសាមញ្ញ ដើម្បី ៖

(១) ហៅថា "អឌ្ឍនខសញ្ញា" ក៏បាន ។

ឥ) ជ្រើសតាំងសមាជិកទាំងឡាយនៃគណៈកម្មាធិការនាយក;

ឲ) ស្ដាប់សេចក្ដីរាយការណ៍ . . . . . . . . . . ;

ឳ) ពិភាក្សាអំពីបញ្ហាទាំងឡាយ . . . . . . . ,

សម្រាប់ប្រើកន្លែងតែមុខលេខ ដែលយកមកប្រើរៀងជាមាតិកា នៅខាងដើមសេចក្ដីនីមួយៗ,

ឧទាហរណ៍:

ការសិក្សា (គឺសាលារៀនទូទៅ) ពោលដោយសង្ខេបមាន ៤ ប្រភេទ[១] គឺ ៖

១) វិទ្យាសិក្សា រៀនវិទ្យាសាស្ត្រផ្សេងៗ មានអក្សរសាស្ត្រជាដើម;

២) បរិយាសិក្សា រៀនរក្សាបុគ្គលកិរិយាមារយាទ;

(១) ស្រង់ពីសៀវភៅ ព្រះពោធិវង្ស (ហ.ត សុវណ្ណវជិរប្បញ្ញោ) ចាងហ្វាងសាលាបាលីជាន់ខ្ពស់ ។

៣) កម្មសិក្សា រៀនកាន់ការ គឺរៀនឲ្យចេះធ្វើការ ថែកស្អាតជំនាញ ;

៤) កាយបរិហារសិក្សា រៀនរក្សារូបកាយ ឲ្យបានប្រកបដោយអនាម័យសុខភាព ។

ក) សំនួរ

វិជ្ជាក្របកបំហៀង ឬ អក្ខរសិក្សា មានរូបសណ្ឋានដូចម្ដេច? សម្រាប់ប្រើដូចម្ដេចក្នុងការសរសេរ? ចូរលើកឧទាហរណ៍មកពន្យល់?

ខ) ចម្លើយ



## (២០) អវគ្គហសញ្ញា[១] (៎)

ខណ្ឌសញ្ញាមួយបែប មានរូបសណ្ឋានស្រដៀងនឹងពងដង្កូវខ្មៅក្រញ៉ង់នេះ (៎) សម្រាប់ប្រើតបទសន្ធិភ្ជាប់ស័ព្ទពីរដែលមានស្រៈនៅជិតផ្ទាល់គ្នា ហើយត្រូវលុបស្រៈមួយចេញ ដោយដាក់ខណ្ឌសញ្ញានេះជំនួស, មានវិធីប្រើដូចគ្នានឹង អាប៉ូស្ត្រូហ្វ៍ (Apostrophe) ឬរាំង (') នេះ (ប្រើចំពោះតែភាសាសំស្ក្រឹត),

ឧទាហរណ៍ :

សោ អបិ > សោ៎បិ, សោ អហំ > សោ៎ហំ, តេ អបិ > តេ៎បិ ជាដើម ;

---

(១) អវគ្គហ : (អានថា: អៈវ៉កគ្រ្គះហៈ) ន. ( សំ. អវគ្រហ :, ម. អវគ្គហ ប្រែថា: "គ្រឿងជំទាស់, គ្រឿងរាំង, ហេតុដែលនាំឲ្យទើសទាក់, ឧបសគ្គ"), (មើលវចនានុក្រមភាគទី ២ ពួកអក្សរ អ)។

បើភាសាសំស្ក្រឹត ដែលសរសេរជាអក្សរឡាតាំង ត្រូវប្រើយ៉ាងនេះ ជា: So' Pi, So' Ham, Te' Pi;

ខាងភាសាបាលី បើយក អាប៉ូស្ត្រូហ្វ៍ (') នេះមកប្រើជំនួស អវគ្រហសញ្ញា (៖) នេះ ត្រូវតាមសម័យនិយមក៏បាន ដើម្បីឲ្យងាយមើលនឹងងាយសរសេរ,

ឧទាហរណ៍:

សោ'បិ, សោ'ហំ, តេ'បិ ជាដើម ។

អវគ្រហសញ្ញា (៖) នេះ ដូចគ្នានឹងខណ្ឌសញ្ញា អាប៉ុស្ត្រូហ្វ៍ដែលប្រើខាងភាសាបារាំង,

ឧទាហរណ៍: (ខាងភាសាបារាំង)

Je Ai > J'ai, Le Homme > L'homme, Le Estomac > L'estomac ETC...;

ញ) សំនួរ

អវគ្រហសញ្ញា មានសណ្ឋានដូចអ្វី? សម្រាប់ប្រើ

តបទអ្វី? មានវិធីប្រើដូចគ្នានឹងសញ្ញាអ្វី? ចូរលើកឧទាហរណ៍មកពន្យល់?

១) ចម្លើយ

* *
*

## ចប់វិធីប្រើខណ្ឌសញ្ញា

# បកិណ្ណកសញ្ញា

សញ្ញា ( < ) នេះ ហៅថា "អាគតសញ្ញា"

សំគាល់សេចក្ដីថា "មកពី",

ឧទាហរណ៍: អត្តូបជីវី < អត្ត + ឧបជីវី "អ្នកចិញ្ចឹមជីវិតដោយអាស្រ័យកម្លាំងរបស់ខ្លួន" ។

ក្នុងគណិតសាស្ត្រសម្គាល់ថា "តូចជាង",

ឧទាហរណ៍:

៣ < ៦ (ចំនួន "៣" តូចជាងចំនួន "៦") ។

* *
*

សញ្ញា ( > ) នេះ ហៅថា "គតសញ្ញា"

សំគាល់សេចក្ដីថា "ទៅជា",

ឧទាហរណ៍:

ក + ិ > កិ;

ខ + ិ > ខិ;

គ + ិ > គិ;

ឃ + ិ > ឃិ;

ង + ិ > ងិ;

កន្ទិតគណិតសាស្ត្រសម្គាល់ថា "ធំជាង"

ឧទាហរណ៍:

១ > ក (ចំនួន "១" ធំជាងចំនួន "ក" ។

* *

*

សញ្ញា (%) នេះ ហៅថា "១ណ្ឌបរិយោសាន" សម្រាប់ប្រើដាក់កន្ទុយបំផុតបង្អស់ នៃសេចក្ដីមួយ ៗ ឬ រឿងមួយ ៗ ដែលចប់ស្រេច ។

១ណ្ឌបរិយោសាន (%) នេះ ខ្មែរមិនសូវប្រើទេ ប្រើនប្រើតែ ១ណ្ឌ (។) នេះឬ ប្រើ ល្បះបរិយោសាន (។ ) នេះតាំងអស់ ។

មានប្រើតែក្នុងការចែកភាគក្នុងចំនួនរយ ត្រូវនឹងពាក្យបារាំងថា (Pourcentage) ហៅថា ភាគរយ (%),

ឧទាហរណ៍:

បំពោះការលក់អសង្ហារិមវត្ថុ ពន្ធប្រថាប់ត្រា គេត្រូវយកដប់ប្រាំភាគរយ (១៥%) លើតម្លៃលក់......;

ឬថា:

បើអ្នកទិញសៀវភៅខ្ញុំយកទៅលក់ ខ្ញុំនឹងគិតរង្វាន់ជូនអ្នកម្ភៃប្រាំភាគរយ (២៥ %) ...... ។

* * *

សញ្ញា (+) នេះ ហៅថា "កាកបាទ" សំគាល់សេចក្ដីថា "នឹង" ឬ "ហើយនឹង",

ឧទាហរណ៍:

ក + ប > កប; កា + ប > កាប ។

១ + ២ = ៣; ៣ + ២ = ៥ ។

* *
*

សញ្ញា (=) នេះ បើប្រើក្នុងអក្សរសាស្ត្រត្រូវសំគាល់សេចក្ដីថា "គឺ, ទៅជា" ឬ "ជា",

ឧទាហរណ៍:

អ + អិ = អេ; អ + ឧ = ឱ;

បើប្រើដាក់ពីក្រោមពាក្យ គឺពីក្រោមបន្ទាត់ នោះរបៀបប្រើដូចគ្នានឹងវង្គុសញ្ញាដែរ, តែអាចបង្អុលបង្ហាញសេចក្ដីឲ្យច្បាស់ជាងវង្គុសញ្ញានោះទៅទៀត,

ឧទាហរណ៍:

បណ្ដាកូនសិស្សដែលចូលប្រឡង ១០ នាក់នោះបាន ជាប់តែ ៥ នាក់ទេគឺ:

ស៊ុន-ដា ១, នាងប័ត្ន-បុប្ផា ១, នាងប៊ុត-លតា ១, ស៊ុខ-ស៊ីរី ១, សេង-វិឡុនា ១;

បើប្រើកន្សែងគណិតសាស្ត្រ ត្រូវសំគាល់សេចក្ដីថា "ស្មើនឹង" ឬ "ត្រូវជា",

ឧទាហរណ៍:

៤ : ២ = ២; ៤ + ២ = ៦ ... ជាដើម ។

* *
*

សញ្ញា (×) នេះ សម្រាប់ប្រើកន្សែងគណិតសាស្ត្រ ប្រែថា "គុណនឹង" ជាសញ្ញាសំគាល់សេចក្ដីថា "ត្រូវបង្កើន ឬ ទ្វេភាគ ឬ បំនួនឲ្យច្រើនឡើង",

ឧទាហរណ៍:

៥ × ២ = ១០ ... ជាដើម ។

— បប់ —

# បញ្ជីសៀវភៅ

## ផ្សាយចេញពីបណ្ណាគារ ប៊ុត-នាង

១– អភិធម្មមាតិកាប្រែ . . . . . . . . . . . . . . . . ៨៥,០០
២– ធប្បករណាភិធម្មប្រែ . . . . . . . . . . . . . . . ៨,០០
៣– ព្រហ្មវិហារកថា . . . . . . . . . . . . . . ១៥,០០
៤– គិហិវិន័យសួរ–ឆ្លើយ (សម្រាប់ឧបាសក) . . . . . ២១,០០
៥– អភិធម្មត្ថសង្គហសង្ខេប . . . . . . . . . . . . . . ៨,០០
៦– អរិយធនកថា . . . . . . . . . . . . . . . . . . ៦,០០
៧– ត្រៃសរណគមនវិធី . . . . . . . . . . . . . . . ១០,០០
៨– សាសនាគឺអ្វី សួរ–ឆ្លើយ . . . . . . . . . . . . ២០,០០
៩– ធម្មរាសី (សម្រាប់ធម្មវិន័យថ្នាក់ឯក–ទោ) . . . . ២០,០០
១០– ត្រៃរត្នវិនិច្ឆ័យ (ពិស្តារ) . . . . . . . . . . . ៣៥,០០
១១– មារាទិវិជ័យ . . . . . . . . . . . . . . . . . ១០,០០
១២– ប្រជុំលិខិត . . . . . . . . . . . . . . . . . ៣៥,០០
១៣– ទម្លាប់ទំនៀម . . . . . . . . . . . . . . . . . ២០,០០
១៤– រាជសព្ទ . . . . . . . . . . . . . . . . . . . ១០,០០
១៥– ច្បាប់បណ្តាំឪពុក . . . . . . . . . . . . . . ៤,០០
១៦– ច្បាប់ហែមហាជន . . . . . . . . . . . . . . . ៤,០០
១៧– ល្បើកឧច–ស៊ីឌឺ (ប្រែចេញពីហ្វាប់ឡាហ្វុងតែណ៏) ១៥,០០
១៨– ចោរបិទមុខ (៥ ខ្សែចប់) . . . . . . . . . . . ១០,០០
១៩– ចោរលួចប្រាក់ (២ ខ្សែចប់) . . . . . . . . . . ១៣,០០

២០ - មគ្គលីផល (៤ ខ្សែចប់) . . . . . . . . . . ៨,១០០
២១ - សុវណ្ណកាមស (៥ ខ្សែចប់) . . . . . . . . . ១០,០០
២២ - នាងវិមានច័ន្ទ . . . . . . . . . . . . . . . . ១១,០០
២៣ - សុភាទន្សាយ . . . . . . . . . . . . . . . . . ៨,០០
២៤ - ព្រេងភាសនាអនាគត . . . . . . . . . . . . . ១៥,០០
២៥ - ព្យាករណ៍សាស្ត្រ (តម្រាកាត់សប្តិ នឹង មើលប្រផ្ទិយ) ១៥,០០
២៦ - តម្រាជាប់ឲ្យល័ត . . . . . . . . . . . . . . ១០,០០
២៧ - ព្រហ្មជាតិទី ១ (ក្បួនទាយគ្រប់យ៉ាង) . . . . . . ៣០,០០
២៨ - — ទី ២ ( — ដ — ) . . . . . ៣០,០០
២៩ - — ទី ៣ ( — ដ — ) . . . . . ៣០,០០
៣០ - ភាសិតសម្រាំង (ទី ១ – ២ – ៣) . . . . . . ១៥,០០
៣១ - អនុពាក្យ (សរសេរតាមសូត្រ) . . . . . . . . ២៥,០០
៣២ - អក្ខរានុក្រមខ្មែរ . . . . . . . . . . . . . . . ៣០០,០០
៣៣ - វិធីប្រើវណ្ណយុត្តិ នឹង ខណ្ឌសញ្ញា . . . . . . . ២៥,០០
៣៤ - ប្រស្នានព្វន្ត (សម្រាប់ថ្នាក់មធ្យមដ្ឋាន នឹង ឧត្តមដ្ឋាន) ៣០,០០
៣៥ - ផាយា - សង្ឃដីកា (បងក្រប) . . . . . . . . ៥,០០
៣៦ - ភាសិតសម្រាំងទី ៤ នឹងទី ៥ . . . . (កំពុងបោះពុម្ព) . .
៣៧ - បែបរៀនអង់គ្លេសឆាប់ . . . . . . . ( — ដ — ) . .
៣៨ - ភាសាបដិវត្តន៍ (ខ្មែរ – បារាំង) . . . ( — ដ — ) . .
៣៩ - គោលសំខាន់នៃប្រវត្តិសាស្ត្រប្រទេសកម្ពុជា ( — ដ — ) . .

* *
*

# ប្រដាប់គ្រូបង្រៀន

១- អក្សរចល័តខ្មែរ (មានស្រៈ, ព្យញ្ជនៈ, គ្រាភ់, សម្ងាប់, ផ្ញើផ្ញើង, លេខ) . . . . . . . . . . . . . . . . . ៣៥រ,០០

២- អក្សរចល័តបារាំង (Lettres Mobiles Français) ៣០,០០

៣- រូបសត្វស្រុក - សត្វព្រៃ - សត្វទឹក (មានច្រើនមុខ) ៤,០០

៤- ទេសភាពវត្ត . . . . . . . . . . . . . . . . ១០,០០

៥- ទេសភាពកំពង់ . . . . . . . . . . . . . . . . ១០,០០

៦- ជីវភាពនៅស្រុកស្រែ . . . . . . . . . . . . ១០,០០

៧- រូបភាពកសិកម្ម (ការភ្ជួររាស់) ផ្ទាំងធំ . . . . . ៣០,០០

៨- សុភាសិតខ្មែរ (មានច្រើនមុខ) . . . . . . . . ៥,០០

៩- គំនូទេសភាពធំ ៗ សម្រាប់តាំងសាលារៀននឹងតាំងលំអគេហស្ថាន (មានច្រើនបែប) . . . . . . . . . .

១០- ការបាត់ថ្នាក់ (អក្សរៈខ្មែរ - បារាំង) រចនាជាអក្សរព័ណ៌ (មាន ១៣ មុខ) (Classement) . . . . . . . ៦,០០

១១- រូបអសុភ (Squelette) . . . . . . . . . . ១០,០០

* *
*

# ដំណឹងពិសេស

បណ្ណាគារខ្ញុំមានទទួលធ្វើអក្សរកាត់គ្រប់បែប (អក្សរខ្មែរ), បើអស់លោក-អ្នក ត្រូវការជាវយកទៅប្រើការក្នុងពិធីផ្សេងៗ, ដូចជា: បុណ្យព្រះសព, បោសព, កឋិន, ផ្កា, សីមា, យីកោដ្ឋ, ឆាមសាលារៀន ឬ បិទបដា ជាដើម នោះសូមអញ្ជើញទៅទាក់ទងនឹងបណ្ណាគារខ្ញុំចុះ បណ្ណាគារខ្ញុំនឹងទទួលធ្វើជូន ។

* *
*

## កំពស់អក្សរដូចមានខាងក្រោមនេះ

| | | | |
|---|---|---|---|
| អក្សរខម | កំពស់តួ ៣៥ សង់ទីម៉ែត្រ | | (មិនគិតជើង - សក់) |
| — | — | ២០ — | ( — ដ — ) |
| — | — | ១០ — | ( — ដ — ) |
| អក្សរឈរ | — | ១៥ — | ( — ដ — ) |
| — | — | ១០ — | ( — ដ — ) |

* *
*

# ប្រដាប់គ្រូបង្រៀន

| | | |
|---|---|---|
| ១ - | អក្សរចល័តខ្មែរ (មានស្រះ, ព្យញ្ជនៈ, គ្រាប់, សម្គាប់, ផ្ញើជើង, លេខ) . . . . . . . . . . . . . . . | ៣៥រ,០០ |
| ២ - | អក្សរចល័តបារាំង (Lettres Mobiles Français) | ៣០,០០ |
| ៣ - | រូបសត្វស្រុក - សត្វព្រៃ - សត្វទឹក (មានច្រើនមុខ) | ៤,០០ |
| ៤ - | ទេសភាពវត្ត . . . . . . . . . . . . . . . | ១០,០០ |
| ៥ - | ទេសភាពកំពង់ . . . . . . . . . . . . . . . . | ១០,០០ |
| ៦ - | ជីវភាពនៅស្រុកស្រែ . . . . . . . . . . . . | ១០,០០ |
| ៧ - | រូបភាពកសិកម្ម (ការភ្ជួររាស់) ផ្ទាំងធំ . . . . . . | ៣០,០០ |
| ៨ - | សុភាសិតខ្មែរ (មានច្រើនមុខ) . . . . . . . . . | ៥,០០ |
| ៩ - | គំនូរទេសភាពធំៗ សម្រាប់តាំងសាលារៀននឹងតាំងលំអគេហស្ថាន (មានច្រើនបែប) . . . . . . . . . . | |
| ១០ - | ការបាត់ប្លាក់ (អក្សរខ្មែរ - បារាំង) រចនាជាអក្សរព័ណ៌ (មាន ១៣ មុខ) (Classement) . . . . . . . . | ៦,០០ |
| ១១ - | រូបឆ្អឹង (Squelette) . . . . . . . . . . | ១០,០០ |

* *
*

ថ្លៃ ២៥រ,០០ ភ្នំពេញ – រោងពុម្ពព្រះបរមរាជវាំង